# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូពគ្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង


*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ឃុនឧត្តមប្រីជា បាប-ពិន . . . ចណ្ដោក . . . . . . . . . . . . . . ៤៥១

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . ពិធីបូជាសពអ្នកឧកញ៉ា ជុំ-មៅ . . . . . . ៤៥៩

លោក ហាន់-យេង . . . . . . រឿងកំពូលកំសត់ (តមក) . . . . . . . ៤៦៤

លោក ញ៉ុក-នូ . . . . . . ច្បាប់ក្រមបរិយាយ (តមក) . . . . . . . ៤៧៧

ព្រះសមុហ៍ឃោសាចារ្យយូរ-ប៊ុណ្ណ សុវណ្ណសាមជាតក ពាក្យកាព្យ(តមកនឹងចប់) ៤៨៣

*ផ្នែកសាសនា*

ពុទ្ធសាសនបណ្ឌិត្យ . . . . . អំពីព្រះរាជទានតាំងសមណស័ក្តិ នៅវត្ត
ឧណ្ណាលោម . . . . . . . . . . ៤៩០

អ្នកអាចារ្យ គី-គឹមស៊ីវ . . . . មត្តាគុភជជាតក . . . . . . . . . . ៤៩៨


ឆ្នាំទី ១៦ — លេខ ៩ ខែសេប្តេម្ប្រ៍ ឆ្នាំ ១៩៤៤ — ដំឡៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

N° 9

M. 8° 1+61
12 - X - 4

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire: Luong Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse: Preah kru Paññalikhito Kao-Sim, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

### Partie littéraire:


| | | Pages |
|---|---|---|
| K'ŭn Ŏtdăm Preichea Chap-Pinn . . . . . . | Băndau (devinettes cambodgiennes) | 451 |
| Luong Nîponmontrei Nhok-Thêm . . . . . . | Compte-rendu de l'incinération de l'Oknha Choum-Mau . . . . | 459 |
| Monsieur Han-Yéng . . . . | Kămpul kămsăt, roman (suite) . . | 464 |
| Monsieur Nheuk-Nou . . . | Chbáp krăm bârĭyay (suite) . . . | 477 |
| Prĕah sămŭk'ósachar You-Ponn . . . . . . | Suvannasāmajātaka, poème (suite et fin) . . . . . . . . . . . | 483 |


### Partie religieuse:


| | | |
|---|---|---|
| Institut Bouddhique . . . | Compte-rendu de la remise solennelle des titres aux nouvaux Reachea kĕană, à Vĕat Unnalom . . . . . . . . . . . | 491 |
| Achar Ky-Kimsiv . . . . | Mandhāturājajātaka. . . . . . . . | 495 |


16e année — N° 9. Septembre 1944 — Abonnement: un an 15$00.

## បណ្ដាំ

# ពាក្យផ្ដើម

កម្ពុជរដ្ឋយើង មានកវីខ្មែរជាតិប្រឌិតពាក្យបណ្ដាំច្រើនបែប មានប្រការផ្សេងៗ ជាចំណោទបញ្ឆិតបញ្ឆៀងប្រៀបប្រាយអំពីភាពលំនាំនឹងកិរិយានៃវត្ថុ-រុក្ខា-លតា-សត្វ នឹងមនុស្ស ទុកសម្រាប់ជនានុជនបណ្ដាំគ្នាទៅវិញទៅមក តាមសប្បាយ ឲ្យស្រាយ ឲ្យរក, ជនានុជនក៏និយមយកជាគតិ បានបណ្ដាំគ្នាតៗមក ជាយូរអង្វែងហើយ ។ ពួកអ្នកដែលចេះពាក្យបណ្ដាំ កាលនឹងបណ្ដាំគេ តែងដាក់កម្រិតគេជាមុនយ៉ាងម៉ឺងម៉ាត់ ថា "បើរកឃើញរួចខ្លួន, បើរកមិនឃើញទេ នឹងលក់" កាលបើអ្នករក, រកមិនឃើញ អ្នកបណ្ដាំគេក៏លក់តាមត្រូវការ ។ ពាក្យលក់មានប្រការផ្សេងៗ តាមយោបល់អ្នកបណ្ដាំប្រឌិតឡើងខ្លះ តាមចាំតៗគ្នាមកខ្លះ, ស្រេចនឹងអ្នកបណ្ដាំគេចង់លក់បែបណា ក៏លក់បែបនោះ, បណ្ដាពាក្យលក់ទាំងអស់ សុទ្ធតែជាពាក្យបន្ទុះបង្អាប់បន្ទាបបន្ថោក ហើយសុទ្ធតែចេញចំឈ្មោះអ្នករក ដើម្បីឲ្យឈឺចិត្តខំគិតរក. ដូចជា "លក់ឈ្មោះ ក ទៅដល់ស្រុកដីក្រហម ឲ្យយកដង្កូវ ៥ ក្អម មកកាយលិទ្ធៗ; លក់ឈ្មោះ ខ ទៅដល់ស្រុកបាសាក់ឲ្យគេវាយគេធាក់ ចាក់ដៃបាក់ជើង; លក់ឈ្មោះ គ ទៅដល់ស្រុកស្រែអំបិល ម្ដាយត្រនិលអាពុកត្រឆោល ម្ដាយបងត្រដោកអាពុកបងណែនណាន់" ជាដើម; លក់ហើយទើបស្រាយបណ្ដាំនោះប្រាប់ៗ បើអ្នករកខ្វាចះថាកចាប់ខ្លួន មិនចង់ឲ្យ

គេលក់ ត្រូវជូនបណ្ណាការដល់គេ, កាលបើជូនហើយ គេក៏ឈប់លក់ គេស្រាយស្រាប់មក ៗ ឯពាក្យជូនបណ្ណាការនោះសោត ក៏មានច្រើនបែប តាមអ្នកកេគេបេះគេត្រូវការ ដូចថា "ជូនប្រាក់១ទូក ជូនឈូក ១ ត្រពាំង ជូនមាស ៥ ឃ្លាំង ៥០ ១ រទេះ លោះខ្ញុំចិនទៅកាប់ចម្ការ លោះខ្ញុំជ្វាទៅជួញសំពៅ មានទាំងមេនាង មកទៅ ហែមុខហែក្រោយ ដៃ ១ ស្លុយទឹក ដៃ ១ ស្លុយប្រេង ប្រាក់ ៥ ជញ្ជីង ជូនដល់ព្រះទុក ប្រាក់ ៥ ជង្រឹក ជូនអ្នកបណ្ដៅ តើអ្នកយកឬទេ?" ជាដើម; អ្នកបណ្ដៅទទួលព្រមថា "យកហើយ" ក៏បណ្ដៅផ្សេងទៀត ៗ

បើនឹងស្រាវជ្រាវរកដើមកំណើតថា ក្នុងសម័យណា កណា ជាអ្នកផ្ដើមបង្កើតពាក្យបណ្ដៅបែបណាឡើងមុនគេនោះ ពុំអាចដឹងបាន; ដឹងបានខ្លះតែត្រឹមថា ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះហរិរក្សរាមា-ឥស្សរាធិបតី ព្រះអង្គ ដួង (ក្នុងព្រះបរមៈកោដ្ឋ) នោះប្រជាជនច្រើនចូលចិត្តបណ្ដៅ, ព្រះករុណាជាម្ចាស់ជីវិតលើត្បូងក៏ទ្រង់សព្វព្រះរាជហឫទ័យដែរ ទ្រង់បានតាំងផ្ដើមបង្កើតពាក្យបណ្ដៅដោយព្រះរាជយោបល់របស់ព្រះអង្គជាច្រើនបែប មានបណ្ដៅដើមទ្រមូង សក ថា "គល់ជាក្អេងអ្នកធង, កណ្ដាលជាធង, ចុងជាបក្សី" ជាដើម ដែលមានក្នុងនេះ ត្រង់លេខ ៦៦ ។

បណ្ដៅដែលមានចំនួនច្រើនជាអនេកប្បការ មិនមែនកើតឡើងដោយស្នាដៃនៃកវីតែម្នាក់ ក្នុងសម័យតែមួយទេ គឺកើតឡើងដោយ

ករីច្រើននាក់ ច្រើនសម័យ ។ បណ្ដាពាក្យបណ្ដៅទាំងអស់នោះ មាន បណ្ដៅជាច្រើន ត្រឹមត្រូវល្អណាស់ គួរឲ្យទឹកស៊ើបអ្នកដែលធ្វើប្រឌិតឡើងជាដំបូងបំផុតនោះក្រៃពេក ដូចបណ្ដៅដំបុកត្រី ថា "រុក្ខាលតាព័ទ្ធបុង មច្ឆាពួនកុង ពួះប្រែបអគ្គី" បណ្ដៅល្មៃមាស ថា "លតានាមជាសុវណ្ណ តែងផុះព័ទ្ធព័ទ្ធ នាដើមព្រឹក្សា" ជាដើម; បណ្ដៅអស់នេះ អ្នកល្មម ៗ មិនអាចប្រឌិតឡើងបានទេ, លុះតែអ្នកចេះភាសាបាលីភាសាសំស្រ្កឹត ទាំងចេះពាក្យឃ្លោងហត់ចត់ ទើបប្រឌិតឡើងបាន ។

ខ្ញុំ ពេញចិត្តនឹងបណ្ដៅជាបុកណាត់ត់នេះ បានជាខំស្វះស្វែងស៊ើបសួរចាស់ៗ. ក្នុងស្រុកទិតមផ្សេង ៗ បានចំនួន ២១៣ បែបយកមករួបរួមរៀបរៀងទុកក្នុងទីនេះ ដើម្បីរក្សាគ្រឿងដំណែលរបស់ខ្មែរកេរ៌អំពីបុកណឲ្យបានឋិតថេរទៅកាលពេលទៅមុខ ទុកជាប្រយោជន៍ដល់ខ្មែរជនជាន់ក្រោយ ដោយយល់ថាជាកិច្ចដ៏ឥតទោស ជាគ្រឿងឲ្យកើតសតិបញ្ញាដល់អ្នកដែលត្រូវការ ។

ខ្ញុំសូមទទួលអំណរគុណយ៉ាងច្រើនចំពោះលោក-អ្នកដែលបានឲ្យពាក្យបណ្ដៅនោះៗ ជាអំណោយដល់ខ្ញុំ, សូមឲ្យលោកអ្នកបានសេចក្ដីសុខ សេចក្ដីចម្រើន ដោយផលនៃអំណោយនេះ ។

ថ្ងៃ ១០ ខែមេ ឆ្នាំ ១៩៥៥

ឃុន ឧត្ដមប្រិជា បាប-ពិន និពន្ធករ

នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ដៅ | ដោះស្រាយ

១- ឯកអគ្គទ្រង់នាមបរ កន្ទុយស្រួចញ៉ែរ ក្អកហើយ
ក្រហែមផង? . . . . . . . . . . . . . . . . តុកកែ

២- ឯកអគ្គទ្រង់នាមបត្តី ទាញយ៉ះជើងពីរ បញ្ចូល
គ្រាប់មួយ? . . . . . . . . . . . . . . . . ប្រណាក

៣- ឯកអគ្គទ្រង់នាមប្រត្យ័ក្ស កន្ទុយដុំប្រាក់ ដុំមាស
សង់ខាង? . . . . . . . . . . . . . . . . ក្ងោក

៤- ឯកអគ្គទ្រង់នាមឯក ដំខ្ពស់អនេក តែពាំបជាង
ស្មៅ? . . . . . . . . . . . . . . . . . . ភ្នំ

៥- ឯកអគ្គទ្រង់នាមព្រឹក្សា ពុកមាត់ដូចឆ្មា ក្រយៅដុំ
ខ្លួន មានគូទជាសង្ក្រសួន ក្ងួនបាត់ពីខ្លួន មិន
ដឹងខ្លួនឡើយ? . . . . . . . . . . . . . ដញ្ជូង

៦- ឯកអគ្គទ្រង់នាមបក្សា មានចិត្តហានក្លា លើស
លុបអស់សត្វនានា ឃើញមនុស្សស្ទុះទៅទិញ
ហៅហានមហិមារកសត្វនានាស្មើគ្មាន? . . . អួស

៧- ឯកអគ្គទ្រង់នាមបក្សា កន់ធំដម្បារ ចង្កេះវៀវ៉ុ
មានជើងតែមួយទល់ដី ប្រឹងប្រាណឃ្មាតខ្មី
ត្រីវ័ធស្មេង ហោះឯអាកាសទន្ទេង កន្ទុយនោះ

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ឯង ដូចគល់ប៉ាំ ចាប់ហោះផ្អើកផ្អោះទន្ទាំ ដូចដៃគេកាំ តាមក្លើមហោស្រព? . . . . . | ខ្លែងក្ទុង |
| ៨— ឯកអង្គទ្រង់នាមបក្សី កន្ទុយអុសដៃ ពាំឈើហោះឡើង? . . . . . . . . . . . . . . . . | ខ្លែងក្ទុង |
| ៩— ឯកអង្គទ្រង់នាមកាត់ មេទៅផុតមិនយំរក កាលណាមេដល់មក លើកបំបៅទើបស្រែកយំ? . . | ស្ទូវផ្កា |
| ១០— ឯកអង្គទ្រង់នាមម្ចាស់ ក្រែកលៀនណាស់ណា ដៃវែងជាងខ្លួន? . . . . . . . . . . . . | បង្កង |
| ១១ – ឯកអង្គា ខាំមិនទំពា ទុកមួយអន្ទើ, ឯកអង្គ រលិតទន្ទំ រលិតទ្ទបុង? . . . . . . . . | អង្គប់កណ្ដារ, ដំបុកត្រី |
| ១២ – ព្រឹក្សាដុះនាខាងផ្លូវ អ្នកផងដើរទៅ ហៅឯងឆ្លើយឯង? . . . . . . . . . . . . . . . | ដើមភ្លូបាត, កណ្ដាលបាត ។ល។ |
| ១៣ – ព្រឹក្សានាមជាបក្សី មិនដុះនៅដី ដុះតែលើគេ? | បញ្ញើក្អែក |
| ១៤ – ព្រឹក្សាផ្កាឯបុង ផ្លែឯគល់? . . . . . . . | ពោត |
| ១៥ – ព្រឹក្សាដុះនាខាងផ្លូវ អ្នកផងគេហៅ ថាវាំងចាស់ណាស់? . . . . . . . . . . . . . . . | ម្ទេសធ្លាស (ម្ទេសខ្ញាំង) |

បណ្ដៅ . ដោះស្រាយ

១៦ - ព្រឹក្សាគេកាត់ជាបីកំណាត់ មានពស់ពេនព័ទ្ធ លើ-
ដើមព្រឹក្សា មានទាំងដូង មានទាំងស្លា មាន
ទាំងថង់ក្រណាញ មានទាំងកងអស្សេរ? . . . ទ្រ

១៧ - ព្រឹក្សាដុះនាមាត់ស្ទឹង អ្នកផងទទឹង ទន់ហើយ
លាទៅ? . . . . . . . . . . . . . . . . ដើមរន្ទា

១៨ - ព្រឹក្សាដុះនាខាងផ្លូវ អ្នកផងគេហៅ ថាកជូរ
ណាស់? . . . . . . . . . . . . . . . . ម្ជូរព្រឹក

១៩ - ព្រឹក្សាដុះនៅព្រៃជ្រៅ អ្នកផងគេហៅ ថាក
មកថ្មី? . . . . . . . . . . . . . . . . ដើមភ្ញៀវ

២០ - សត្វមួយមកពីស្រុកឯជើង ក្បាលទើងម៉េង ជើង
ប៉ុនស្នប់? . . . . . . . . . . . . . . . . ដំរី

២១ - សត្វមួយមកពីស្រុកចិន កន្ទុយសំទុន ស៊ីក្បាល
មនុស្ស? . . . . . . . . . . . . . . . . កន្ត្រៃ

២២ - សត្វមួយមកពីស្រុកលើ បេះធ្វើអំពើ ឲ្យមនុស្ស
ឆ្កួតអស់ទាំងស្រុក? . . . . . . . . . . . ចាបស៊ីស្រូវស្រែ

២៣ — សត្វបួនប្អូនឈ្មោះតែមួយ សត្វបីពាងស្រួយ
សត្វមួយពាងទន់? . . . . . . . . . . . ក្អែកគោក, ក្អែកទឹក, អណ្តើកក្អែក, ត្រីក្អែក,

បណ្តៅ | ដោះស្រាយ

២៤ - សត្វបួនបួនឈ្មោះដូចគ្នា: មួយនៅគង្គា, មួយនៅអាកាស, មួយនៅព្រៃផ្តសផ្កាស, មួយនៅខ្ញុំគេ? . . . . . . . . . . . . . . . . . . . ក្រពើ, ផ្កាយក្រពើ, វល្លិក្រពើ, ក្បាលក្រពើរទេះ

២៥ - សត្វបួនបួនឈ្មោះតែមួយ: សត្វមួយតែងព្រួយបម្រើទ្រព្យគេ, សត្វមួយបិតនៅនាអាកាសអាចារ្យលោកប្រែ ឃើញយប់បាត់ថ្ងៃ, សត្វមួយនៅនាទីជលាស័យ ចិត្តកាចក្រៃ សាហាវយង់ឃ្នង, សត្វមួយបិតនៅនាព្រៃក្បាផង អាចារ្យលោកចង ជាពាក្យបណ្តៅ? . . . . ក្បាលក្រពើរទេះ, ផ្កាយក្រពើ, សត្វក្រពើ, វល្លិក្រពើ

២៦ - សត្វមិនមានឈ្មោះតែមួយ មានស្លាបប្រាំមួយ មានជើងដប់ពីរ? . . . . . . . . . . . . សេះ, ក្រសេះ, កណ្តូបសេះ

២៧ - សត្វមួយមកពីស្រុកឯជើង ក្បាលទូលក្អើង ជើងមានស្នែង? . . . . . . . . . . . . មាន់

២៨ - សត្វមួយឥតឆ្អឹង កើយតែខ្នង ដល់មាន់រងាវរួច ចេញដួងពីក្អក? . . . . . . . . . . . ក

បណ្ដាំ ដោះស្រាយ

២៩- សត្វមួយមកពីស្រុកឯលិច កន្ទុយវែងៗ ប្រមុះមានដែង? ដ្រិក

៣០- សត្វមួយមកពីដើមមេឃ ឃ្លានអាហារខ្លាំងពេក

ចាប់បានទន្សាយលែងក្រោក ធំណាមិនឲ្យត្រូ

ស្រោក ខ្លាចត្រូដល់មនុស្សលោក គេក្រើកខ្មៀវ

ខ្មារ? . . . . . . . . . . . . . . . . . . . . រាហូចាប់ច័ន្ទ

៣១- សត្វមួយមកពីស្រុកឯលិច ក៏ក៏គិចៗ ដើរក៏កប់

រយ? . . . . . . . . . . . . . . . . . . . . ក្អែប, ម្រើមព្រះ

៣២- សត្វមួយទំលើខ្សែដែក ភ្នែកប៉ុនពងមាន់? . . ភ្លើងអគ្គិសនិ

៣៣- សត្វមួយនៅតែក្នុងរណ្ដៅ ឥតមានគេហៅ

ងើយឡើងខ្លួនឯង(*)? . . . . . . . . . . . . ផោម

៣៤- សត្វមួយអង្គុយខ្ពស់ជាងឈើ ឃើញគ្នាក៏មក

ច្រើនជើងមាត់សៀញ? . . . . . . . . . . . . ផ្ដែ

៣៥- សត្វមួយដើរទ្រេកៗ លើទំពក់ចូលព្រៃ? . . . . . ផ្ដែ

៣៦- សត្វមួយនៅតែក្នុងទឹកកក់ៗ ខ្លួនទន់ទ្បេកឡេក

ឥតឆ្អឹងឥតឆ្អែង? . . . . . . . . . . . . . . ឈ្លើង

៣៧- ដើមប៉ុនអង្រែ ផ្លែប៉ុនអង្រឹត? . . . . . . . . . ទន្សែ

---

* ន័យថា ជាញរោម មុនប្រមុះ។ ។ (មានត)

ពិធីបូជាសព

# អ្នកឧកញ៉ា ជុំ-ម៉ៅ អនុមន្ត្រីលេខ ៣ នៅក្រសួងសេដ្ឋកិច្ច

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

រៀបរៀង

អ្នកឧកញ៉ា ជុំ-ម៉ៅ ទទួលអនិច្ចកម្មនៅមន្ទីរពេទ្យធំក្រុងភ្នំពេញ ដោយរោគបុកទឹងធ្លាក់ឈាម ក្នុងថ្ងៃអាទិត្យ ២០ សីហ ១៩៤៤ ក្នុងកំណត់អាយុ ៤៤ ឆ្នាំ ។ ពួកក្រុមគ្រួសារទាំងក្រុមញាតិបាននាំសពអ្នកឧកញ៉ា យកមកដំកល់ទុកនៅគេហស្ថាន ផ្លូវបេលក្រែ ក្រុងភ្នំពេញ ដើម្បីធ្វើបុណ្យបញ្ជូនផលទៅដល់វិញ្ញាណក្ខន្ធរបស់សពតាមទំនៀមស្រុក ។

ថ្ងៃ ២១ សីហ ឆ្នាំ ១៩៤៤ វេលាម៉ោង ១៦ គេបានរំកិលសពចុះពីគេហស្ថានយកទៅដំកល់លើរទេះសេះ ដើម្បីនាំដង្ហែទៅបូជានៅទីប៉ាឆា មុខវត្តបទុមវតី ក្រុងភ្នំពេញ ។ នៅឱកាសនោះ មានក្រុមគ្រួសារទាំងញាតិមិត្តទាំងឡាយជាចំនួនច្រើន ព្រមដោយពួកអ្នករាជការតូច-ធំជាច្រើនក្រុមច្រើនក្រសួង ក្នុងក្រុងភ្នំពេញ សឹងបាននាំគ្នាទៅជួយហែហមអមសពអ្នកឧកញ៉ាជាអឹកធឹក ។ នៅតាមរយៈផ្លូវដែលដង្ហែសពទៅនោះ គេបាននិមន្តព្រះសង្ឃនៅវត្តនានាឲ្យមករង់ចាំបង្សុកូលសពជាច្រើនរយៈវៀង ៗ ទៅ ទម្រាំតែទៅដល់ទីប៉ាឆា មុខវត្តបទុមវតី ។

លុះគេរំកិលសពដាក់ដំកល់ក្នុងបាកុំយ៉តហើយ ទើបមានក្រុមតា-ហានកងកិត្តិយស ១ ក្រុមមកឈរគំនាប់ជាកិត្តិយសដល់សពអ្នកឧកញ៉ា ជាបដល់វេលាបូជាភ្លើងសព ។ មុនពេលបូជាសព គេបាននិមន្តព្រះសង្ឃវត្តបទុមវតីមកធាកនឹងបង្សុកូលតាមទំនៀម ។ នៅឱកាសនោះនៅមានមន្ត្រីធំ-តូច នឹងញាតិមិត្តជាច្រើនគាមទៅជួយក្នុងពិធីបូជាសពនឹងសំដែងសេចក្តីគោរពអាល័យដល់សពអ្នកឧកញ៉ា ។ ក្នុងចំណោមពួកមន្ត្រីទាំងនោះ ខាងមន្ត្រីបារាំង មានលោកទីកូឡាស៍ ជានាយកក្រសួងប្រៃសាសនោបាយ តំណាងលោកឡឺរេស៊ីដង់ស៊ុបេរីយើរជាដើម ។ ខាងមន្ត្រីខ្មែរ មានលោកអ្នកឧកញ៉ាអគ្គមហាសេនាអ៊ឹង-អ៊ី រដ្ឋមន្ត្រីក្រសួងវាំង, ព្រះឃ្លាំងនឹងធម្មការជាដើម ។ ចំណែកខាងបព្វជិត មានព្រះតេជព្រះគុណព្រះពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ជាដើម ។

កាលពួកភ្ញៀវបានមកសន្និបាតជួបជុំព្រមព្រៀងគ្នាហើយ ទើបគេចែកផ្កាច័ន្ទន៍សម្រាប់ដាក់បូជាសពដល់ពួកភ្ញៀវទាំងអស់ រួចហើយទើបគេអញ្ជើញលោកទីកូឡាស៍ តំណាងលោកឡឺរេស៊ីដង់ស៊ុបេរីយើរឲ្យជុតធ្នូនភ្លើងជាដំបូង ហើយពួកមន្ត្រីតូច-ធំព្រមដោយពួកញាតិមិត្តក៏នាំគ្នាតែសងទៅដើម្បីដាក់ផ្កាច័ន្ទន៍បូជាសពតាមទំនៀម ។

* *
*

## អំពីគុណសម្បត្តិអ្នកឧកញ៉ា ជុំ-ម៉ៅ

### កាលនៅធ្វើការក្នុងពុទ្ធសាសនបណ្ឌិត្យ

អ្នកឧកញ៉ា ជុំ-ម៉ៅ បានចូលទៅធ្វើការក្នុងព្រះរាជបណ្ណាល័យកម្ពុជា គឺមន្ទីរពុទ្ធសាសនបណ្ឌិត្យសព្វថ្ងៃនេះ ក្នុងឆ្នាំ ១៩២៦ ក្នុងសម័យដែលលោកស្រី ស៊ុយសាន កាប៉ុឡែស ជាចាងហ្វាងព្រះរាជបណ្ណាល័យ ។ វេលានោះ អ្នកឧកញ៉ាទើបនឹងមានស័ក្តិយសជាទីក្រមការបំរើរាជការនៅឡើយ ។ នៅវេលាដែលក្រមការ ជុំ-ម៉ៅ នៅធ្វើការក្នុងព្រះរាជបណ្ណាល័យនោះ លោកបានខំយកចិត្តទុកដាក់ពិនិត្យសិក្សាអក្សរសាស្ត្រខ្មែរ ត្រាតែបានចេះដឹងស្ទាត់ជំនាញបានជារាជការតាំងឲ្យធ្វើជាក្រមជំនុំ ១ ក្នុងពួកក្រមជំនុំវចនានុក្រមខ្មែរ ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយសព្វថ្ងៃនេះ ។ កិច្ចការស្នាដៃធំៗ ដែលលោកបានធ្វើទុកក្នុងពុទ្ធសាសនបណ្ឌិត្យ ដែលរាជការបានបោះពុម្ពផ្សាយរួចមកហើយ ច្រើនតែជារឿងដែលលោកបានប្រែពីភាសាបារាំងសែសមកជាខេមរភាសា គឺ សៀវភៅ អំពីព្រះពុទ្ធសាសនា ១, ព្រះរាជប្រវត្តិព្រះបាទជ័យវរ្ម័នទីប្រាំពីរ ១, រឿងឯកសហស្សរាត្រី ឬ មួយពាន់មួយយប់ ១, (តែរឿងខាងក្រោយនេះ ប្រែមិនទាន់ចប់ ដោយហេតុត្រូវផ្លាស់ទៅធ្វើការនៅទីដទៃទៀត) ។

ក្រៅអំពីកិច្ចការស្នាដៃខាងលើនេះ លោកត្រូវទទួលមុខការរៀបបំផុសរឿងសម្រាប់ចុះផ្សាយ ក្នុងទស្សនាវដ្តី កម្ពុជសុរិយា ដែលត្រូវបោះពុម្ពផ្សាយរាល់ៗខែ ចាប់តាំងអំពីទស្សនាវដ្តីនេះកកើតឡើងក្នុងឆ្នាំដំបូង (១៩២៦) ។ ហេតុនេះហើយ បានជាគេឃើញមានឈ្មោះលោកក្រមការ ជុំ-មៅ ជាប់នៅនឹងរឿងទាំងឡាយ ដែលមានចុះផ្សាយក្នុងកម្ពុជសុរិយា នៅវេលាដែលៈលោកធ្វើការក្នុងមន្ទីរនេះ អស់រយៈវេលា ៨ ឆ្នាំ គឺ តាំងពីឆ្នាំ ១៩២៦ រហូតដល់ឆ្នាំ ១៩៣៤ ។

មួយវិញទៀត កិច្ចការដែលត្រូវបកប្រែភាសាក្តី ការប្រែរឿងឬសេចក្តីផ្សេងៗ ពីបារាំងមកជាខ្មែរ ដូចជាសុន្ទរកថានិងបាឋកថាជាដើមក្តី ទាំងនេះជាមុខក្រសួងរបស់អ្នកឧកញ៉ា ជុំ-មៅ ទាំងអស់ ត្រាតែលោកមានកេរ្តិ៍ឈ្មោះយ៉ាងល្បីល្បាញ ក្នុងវិជ្ជាមុខនេះ ។ ក្រៅអំពីនេះ លោកត្រូវទទួលបង្គាប់ផ្ទាល់អំពីចាងហ្វាងក្រសួង ដើម្បីបង្គាប់បញ្ជាកិច្ចការសព្វសព៌ ដល់ពួកភ្នាក់ងារក្នុងក្រសួង ។ កិច្ចការទាំងពួងក៏ប្រព្រឹត្តទៅបានដោយរៀបរយស្រួល មិនដែលមានរឿងនាំឲ្យកើតថ្នាំងថ្នាក់អាក់អន់ចិត្តដល់អ្នកធ្វើការក្រោមបង្គាប់ដល់ម្តងឡើយ ។ ពួកភ្នាក់ងារក្នុងមន្ទីរពុម្ពសាសនបណ្ឌិត្យ តែងមានចិត្តស្រឡាញ់រាប់អានលោក ដរាបដល់លោកចេញចាកចោលមន្ទីរនេះទៅ សឹងមានសេចក្តីអាឡោះអាល័យស្តាយរាល់ៗគ្នា ។

អ្នកឧកញ៉ា ជុំ-មៅ ក្នុងវេលាដែលលោកនៅធ្វើការក្នុងព្រះរាជបណ្ណាល័យនោះ សឲ្យគេឃើញសមត្ថភាពរបស់លោកយ៉ាងជាក់ច្បាស់ គឺជាអ្នកមានសតិបញ្ញា និងបដិភាណភ្ញៀវជាចំណាប់, អាចយល់កិច្ចការពាក់ជ្រៅខុសត្រូវបានដោយរួសរាន់, ជាអ្នកស្ទាត់ជំនាញក្នុងកិច្ចការជាមុខក្រសួងរបស់ខ្លួន, ចំពោះវិជ្ជាប្រែភាសា ពីបារាំងមកជាខ្មែរនោះ ទុកជាពូកែឯក ៗ បាន, ព្រោះលោកនេះជាអ្នកមានចំណេះចេះដឹងល្អ ទាំងខាងភាសាខ្មែរ ទាំងខាងភាសាបារាំង ។

ពុទ្ធសាសនបណ្ឌិត្យមានសេចក្ដីស្ដាយ និងអាឡោះអាល័យជាពន្ទឹកចំពោះមរណភាពនៃមិត្តមួយនេះ ដែលធ្លាប់ធ្វើការមានថ្វីដៃមកហើយ ៗ មិនគួរគប្បីសោះឡើយ ដែលមច្ចុរាជយកបង្គំផ្ដាច់ផ្ដិលជីវិតមនុស្ស ៌ មានអាយុមិនទាន់ដល់កំណត់អាយុក្ស័យត្រឹម៤៤ឆ្នាំប៉ុណ្ណោះ, នៅក្នុងវ័យកំពុងពេញកំឡាំងកាយ កំឡាំងសតិបញ្ញាស្មារតី.. ..ឱអនិច្ចា! គួរឲ្យស្រណោះ គួរឲ្យអាឡោះអាល័យ គួរឲ្យសោកស្ដាយណាស់ ៗ

ឱ! មច្ចុរាជអ្នកឥតមេត្តាប្រណី ឱ! សង្ខារសព្វសត្វទាំងឡាយមិនទៀងសោះឡើយ ៗ

---

## កំពូលកំសត់

## លោកបាក់-យ៉េង រៀបរៀង

(តមក)

លុះមេប្រយោគហៅឈ្មោះឲ្យចូលប្រឡងហើយ កុមារទាំងឡាយក៏ស្រូចូលទៅ មានចិត្តថប់បារម្ភតែរៀងខ្លួន ភិតភ័យញ័រជើងដូចជាស្រាលខ្លួនដើរស្ទើរមិនជាប់ដី នាំគ្នាអង្គុយតាមលេខរបស់ខ្លួនរួចប្រុងប្រៀបដំកបន្ទាត់ ចាំមេប្រយោគហៅមេសូត្រ ខ្លះចាប់ដងប៉ាកកាញ័រដៃសរសេរពុំចង់កើត ។ ដេញប្រយោគមួយមុខរួចហើយ ក៏ឈប់សម្រាក ៥ នាទី នាំគ្នាសាកសួរពីពាក្យសរសេរចង់ដឹងខុសត្រូវ ឈ្មោះណាធ្វើខុសតិចក៏ត្រេកអរសោទរឡើង អ្នកណាធ្វើខុសច្រើនក៏មុខខ្មៅប៉ែចង់យំ ។

លុះប្រឡងគ្រប់មុខហើយក៏រង់ចាំដល់សំរេច ថ្ងៃនោះឯងអ្នកប្រឡងទាំងប៉ុន្មាន អរផងភ័យផងមិនច្បាស់ក្នុងចិត្តតើនឹងជាប់ឬធ្លាក់ ដល់គេហៅថាឈ្មោះខ្លួនជាប់ហើយក៏លោតកញ្ឆេង សប្បាយចិត្តចូលទៅឲ្យគេសួរមាត់ទទេទៀត ឈ្មោះណាធ្លាក់ក៏ស្រពោនមុខ ខ្លះយំផងទៀតកៃដៃគ្នាវិលទៅផ្ទះវិញដើរមួយៗ ជាទុក្ខ ព្រោះត្រូវចាំមួយឆ្នាំទៀតបានមកប្រឡងសាជាថ្មី ថ្ងៃនុក្កប្រាប់គ្នាគ្រូឲ្យអាសូរកុមារទាំងនោះពេកណាស់ ទីឯអាណិតដល់មាតាបិតាដែលចំណូនបុត្រមក ទឹកសង្ឃឹមថានឹងបានឡើងត្រឡប់មកធ្លាក់ដូច្នេះ ។

កាលបើសួរមាត់ទទេបរិបូណ៌ហើយ កម្មការខាងប្រឡងក៏ប្រកាសឈ្មោះអ្នកជាប់ឡើង ដែលនាំគ្នាហ៊ោខ្ញៀវខ្ញារព្រៀងកំ ដោយសេចក្ដីសប្បាយ ចំណែកសុកិទ្រក៏ជាប់បានលេខ ១ ជាប់គេជាងឯង ត្រូវមេប្រយោគសរសើរគ្រប់គ្នា កុមារសប្បាយចិត្តណាស់ ស្ទុះចេញមកឱបឪពុក នៅពេលនោះស្រាប់តែសូរសំឡេងដែលខ្លួនធ្លាប់ឮស្រែកហៅឈ្មោះខ្លួនយ៉ាងពីរោះ សុកំទ្រក្រឡេកមើលទៅក៏ឃើញម្ដាយបក់ដៃហៅពីឡានមក ទឹកស្មានជាយល់សប្តិ ដល់ម្ដាយបើកទ្វាររថយន្តចុះមកក៏រត់ទៅឱបម្ដាយយំរកគ្នាទាំងពីរនាក់ ។

ក្នុងវេលាកំពុងប្រឱបគ្នានោះ អ្នកទាំងពីរមានសេចក្ដីសោមនស្សលើសលុប មិនបាននិយាយស្ដីរកគ្នាទេ តែដវ័នមូលមួយ ពីព្រោះដវន-ជាតិដែលអន្តរធានបាត់ទៅជាយូរមកហើយ បានត្រឡប់ចូលមកក្នុងខ្លួនវិញគ្រាន់នឹងកក់ក្ដៅ រលាយទុក្ខទាំងប៉ុន្មានបាត់មួយរំពេច ភ្លេចនឹកថាមានគេឈរមើលជុំវិញខ្លួន ចំនួនជា ១.០នាក់ ក្រោយមក បានសាសងរកគ្នាកើតយកដៃជូតទឹកភ្នែក រួចមាតាសួរបុត្រថា "កូន! ម្ដាយដឹងថាថ្ងៃនេះគេប្រឡង បានជាម្ដាយមកក្រែងជួបនឹងកូន ឱកូនសំឡាញ់មាសម្ដាយអើយ ឯងសុខសប្បាយទេឬតាំងពីម្ដាយបែកមក ម្ដាយចុងឯងគេមិនសូវធ្វើបាបទេឬអ្វី? ចំណែកម្ដាយគេងតែទុក្ខរងរំលឹកដល់

កូនកល់ពេល ។ មួយវិញទៀត ឯងបានឃើញតាព្រៃដែរឬអ្វី? អើឥឡូវ កូនប្រឡងជាប់ហើយល្មមកូនមកនៅនឹងម្ដាយមក" ។

សុភិទ្រនិយាយរឿងរបស់ខ្លួនជូនម្ដាយស្ដាប់សព្វគ្រប់ហើយ ក៏បញ្ចប់សេចក្ដីថា "អ្នកអើយ! ខ្ញុំមកភ្នំពេញណាក៏បាន តែឪបាមិនអនុញ្ញាតឲ្យមកតែទុកជាយ៉ាងណាក៏កូនមករកអ្នកមិនខាន ចំណែកតាព្រៃនោះ ហោរហាក់ស្លាប់ទៅហើយ" ។

សោភិតចាំកូនយូរពេក ក៏ស្រែកតៀនឲ្យឆាប់ពីចំងាយមក សុភិទ្រអួលដើមកលាម្ដាយរបស់ខ្លួន រួចដើរតាមឪពុកទៅ ។

លុះដល់ទីសំណាក់ ពុកសោភិតប្រកាសប្រាប់ប្អូនស្រីថានឹងត្រឡប់ទៅស្រុកវេលាព្រឹកឡើង សុភិទ្រក៏ស្លុតចិត្តបរិភោគអាហារមិនឆ្ងាញ់ ក្រៀមមុខពុំរកពាក្យស្រះពោនស្រពន់ស្ងប់ស្ងួល ឧបមាដូចជាកូនមាន់ដែលក្មេងលេងច្រើន នឹកឃើញដល់សំដីរបស់ម្ដាយខ្លួន សម័យយល់រូបរបស់អ្នកជាប់នឹងក្មេក ចិត្តមិនចង់វិលទៅស្រុកវិញសោះ តែគាត់ចេញពីភ្នំពេញនៅវេលាព្រឹកស្អែកនេះ ដោយមិនដឹងជាដល់ពេលណានឹងបានវិលត្រឡប់មកវិញ ទុកអនិច្ចាអើយ ។

ម្ដាយមីងនឹកអាណិតក្មួយណាស់ ទើបអង្វរសោភិតឲ្យទុកក្មួយនឹងគាត់ហើយ គាត់នឹងចិញ្ចឹមឲ្យរៀនសូត្រទៅទៀត តែសោភិតមិនព្រម លុះផុតស្វាក់គាត់លបនិយាយជាមួយនឹងក្មួយគាត់ថា "បើឯងមក

ឯងចាំផ្ទះមីងបានទេ ឯងមកនៅនឹងមីងចុះ ចាំមីងជួយរកម្ដាយឲ្យឯង ឯងកុំព្រួយពីអ្វីទាំងអស់ ស្រេចនឹងមីងរកចិញ្ចឹមឯងឲ្យឯងរៀនសូត្រ" ។

លុះព្រឹកឡើង សុកិន្ទ្រក៏លាម្ដាយមីងឡើងឡានវិលទៅស្រុកវិញ លាស្រុកភ្នំពេញ លាម្ដាយសំឡាញ់របស់ខ្លួន ដែលពុំបានឃើញមុខ និយាយផ្ទាល់មាត់សោះ ។

## បទទី ១៣

## ធម្មជាតិ! ធម្មជាតិ!

សត្វតាវើយំក្រៃទៀបព្រឹក រំលឹកកសិករឲ្យ ចេញទៅកាន់វាលស្រែ ឯសត្វមាន់ទទះស្លាបពីរបីដងរងាវសោ៊ន ដាស់សញ្ញាជាតិរបស់វាឲ្យក្រោកឡើង ភូមិទាំងមូលក៏ចេញចាកទ្រាអ៊ូអរបន្តិចម្ដង ៗ នៅពេលនោះ សុកិន្ទ្ររៀបចំបោសច្រាសផ្ទះសម្បែងស្អាតបាត រួចដាំបបរទុកជូនឪពុកម្ដាយរបស់ខ្លួន ។ ដល់បែកបច្ចូសសម័យ ទើបចុះដណ្ដើរដើរតាមផ្លូវទៅកាន់ស្រែ ព្រោះគេគិតគាន់តែចាស់ហើយធ្វើការពុំសូវម៉ា ទើបឲ្យក្មេងអាយុ១៣ឆ្នាំទៅមើលកម្មករផងនួស ។

ដើរដល់ផ្ទះប្អូនចិញ្ចឹម សុកិន្ទ្រក៏ឈប់ស្រស់ស្រូបជាមួយនឹងសាលី រួចនាំជូនដំណើរបងវេចកញ្ចប់បាយនឹងម្ហូបឲ្យ ។ សុកិន្ទ្រក៏ត្រឡប់ទៅតែម្នាក់ឯងតាមផ្លូវតូច មានស្មៅទៀរស្រងាត់សងខាងប្រកបដោយស្លឹកស្រស់ញញឹមជាប់ទឹកសន្សើម ដែលត្រូវពន្លឺព្រះអាទិត្យទើប

ទឹងរះក៏ភ្លឺផ្លេក ៗ ដូចត្បូងទទឹម ។ មានផ្កាឈើរីកយដេរដាសក្រអូប ឈ្ងុយឈ្ងប់ សមអាកាសត្រជាក់ល្អផង គួរឲ្យទឹកចង់ស្រែកច្រៀងឲ្យពេញសំឡេង ។

មានពួកក្មេងគង្វាលគោស្វាបបៀមពត់ខ្លួនពត់ប្រាណតាមផ្លូវដើម្បីទឹងកំចាត់បង់ខ្លួនងងុយងោកងក់ ដើរមួយ ៗ តាមក្រោយគោរបស់ក់ សត្វសំឡូតទាំងនោះ ហ្វោះដើរតាមបង្អាក់ស្លូបង្រួញទឹងត្រដោកត្បៀវនៅករបស់វា កាត់មួយរត្តិកាលបាត់រូបឯទីឆ្ងាយឯណោះ លុះដល់វេលាប្រៃផ្ទះហើយ ក្មេងទាំងនោះលែងគោឲ្យស៊ីស្មៅតាមចិត្ត រួចនាំគ្នាប្រឡែងលេងជាសប្បាយអឹងកងទាំងព្រឹកព្រហាម ។

ចំណែកឯសុកន្ធកុមារ ចាត់ការឲ្យពួកកម្មករគោមមុខក្រសួងហើយ ក៏គេចមករត់លេងជាមួយនឹងក្មេងឃ្វាលគោ តែលុះឃើញក្មេងទាំងនោះកខ្វក់ពេក ក៏ញញើតលែងហ៊ានទៅជិត នឹកគិតក្នុងចិត្តថា ម្ដេចក៏គេបេះតែឲ្យដីជាប់ប្រឡាក់នឹងខ្លួនផ្ញុំក្ងានអាក្រក់ដូច្នេះ ចិត្តស្ទើរថាល្អពេកដូចម្ដេចក៏មិនជំរះក្អែលចេញ ធ្វើម្ដេចនឹងបានរូបកាយល្អទៅអេះ ទើបនឹកចង់ណែនាំក្មេងទាំងនោះឲ្យសំអាតខ្លួន ។ ម្យ៉ាងវិញទៀតភាសារបស់គេក៏ប្លែកដល់ត្រចៀកអ្នកពន់ពេក ធ្លាប់តែឮពាក្យសុភាពពីរោះតាប់ចិត្ត មកឮសំដីមិនល្អដូច្នោះ មានដេរគ្នាជាដើមទឹកត្រាន់មិនចង់ឲ្យឮសោះ ។

តែដោយចង់ឲ្យជាតិរបស់ខ្លួនថ្លៃថ្លា ទើបអស់សង្កត់ចិត្តចូលទៅដិតក្មេងទាំងនោះ និយាយពន្យល់ពីឡាកហានុសិខាននៃអនាម័យ រួចបានវិលទៅត្រួតត្រាមើលក្រោលគោរបស់ខ្លួន ឃើញថានោះជាទីបដិ-កូលក្រៃលែង ទើបបង្គាប់ឲ្យមនុស្សម្នាផ្លាស់ចំបើងដាក់ឲ្យគោដេករាល់ៗថ្ងៃ ប្រើឲ្យផ្លាស់ខ្សែបង់ជាប់ទាំងអស់ ហើយថែសំអាតបសុសត្វទាំងនោះឲ្យល្អ ហាមមិនឲ្យប្រើការហួសកំណត់ មិនឲ្យវាយដោយឥតត្រាប្រណី ឯសំដីរបស់សុកិន្ទ្រសោត ក៏ផ្អែមល្ហែមគួរឲ្យស្តាប់ អ្នកទាំងអស់គ្នាក៏ពេញចិត្តធ្វើតាមទាំងអស់ ។

ចាប់តាំងពីកុមារចូលត្រួតត្រាមក ស្រែចំរើនផលជាច្រើនជាងរាល់ឆ្នាំ ព្រោះអ្នកបានពន្យល់អ្នកធ្វើឲ្យប្រតិបត្តិតាមវិធីដែលអ្នកបានរៀនពីសាលាមក ហើយឲ្យដាក់ជីដីឲ្យមានជីជាតិល្អ ពួកកម្មករទាំងប៉ុន្មានក៏សប្បាយចិត្តគ្រប់ ៗ គ្នា រហូតដល់សត្វគោមានសាច់ធាត់ល្អហើយស្អាតផង ពួកក្មេងគោបាលក៏ផ្លាស់ភេទខុសពីដើម អ្នកណាហើយនឹងនឹកស្មានថា អ្នកទាំងនោះជាអ្នករកស៊ីកកាយព្រះធរណី !

ឯសោភិតនឹងសុវណ្ណបុប្ផា បានប្រាក់កាសច្រើនចូលទូដែក ក៏មានចិត្តសាទរពេញចិត្តនឹងកូនពន់ពេក តែមិនបានសំរាលការងារឲ្យខ្លះផងទេ សុកិន្ទ្រក៏គ្មានពេលទំនេរឈប់សម្រាកខ្លួន នៅពេលដែលកំពុងពេញកំលាំង អត្តភាពកំពុងរីកកំពុងឡើងសម្រស់ ដល់ត្រូវ

បំពេញនាទីជូនហួសកំរិត ក៏ទ្រុឌទ្រោមទៅមិនពេញបរិបូណ៌ កុមាររស់នៅក្នុងពិភពលោកពោលតែម្នាក់ឯង គ្មានអ្នកឯណាចូលសមាគមផង ក្រៅអំពីនាងសាលីប្អូនចិញ្ចឹម ទំពក់ត្រឹកទ្រូងផុតទៅតែដដែល ៗ ប្រាសចាកអលង្ការទីទំរសេចក្ដីត្រេកត្រអាល តែកុមារមិនបានគក់ស្លុតដល់ការហត់នឿយតាំងនោះឡើយ ៗ

ទុកជាមនុស្សជាតិតាំងមូលៈតបដំសេច ក្រៅពីសមាគមរបស់គេក្ដី ទុកជាគ្មានសេចក្ដីពប់គាន់អំពីសំណាក់វង្សញាតិក្ដី ធម្មជាតិតែងតែទទួលកក់ភាក់រក្សាជាដកប មិនចេះធុញទ្រាន់ មិនចេះពេបជ្រាយ មិនចេះឡូកឡូយ ជាមិត្រមានគារម្មណ៍ត្រជាក់ មានអធ្យាស្រ័យទុនលំទោនដល់អ្នកពលគ្នា ជាមិត្រមិនចេះលេងកលមិនចេះយន់យួង ប្រកបដោយបដិ-គាណយ៉ាងវិសេស រមែងប្រស្រ័យគេដោយមធុរពចា ពោលគឺសត្វបម្រែងបក្សីបក្សាទីងស្លឹកឈើ ត្រខ្យល់បក់ព្រមទាំងសូរសត្វល្អិតយំលួងលួយ អាចឲ្យសុខដល់អ្នកគក្ដីរកមិនមានថ្ងៃណាឲ្យសៅហ្មងចុះ ៗ

ចូនណាធម្មជាតិនេះមានសភាពពុំសូវកបសា តែកាលបើដៃមនុស្សរចនាហើយក៏ស្អាតបង្គាប់ ហុចផលឲ្យបរិបូណ៌សុកសម្ភទីងរកអ៊ីឲ្យប្រសើរជាងការរកកាយព្រះធរណីនេះគ្មានទេ ជាការពិបាកនាំឲ្យហត់នឿយក៏ពិតមែនហើយ តែជាជាការបំពេញសាធារណ៍ប្រយោជន៍ គឺជាដំដីតាមត្រូវការ តែគោងតែខំប្រឹងប្រែងផង ៗ មួយវិញទៀត ជាហេតុ

នាំឲ្យមនុស្សមានកំឡាំងកំហែង  ទឹងបរិភោគអាហារក៏មានឧជារស ហើយទឹងនាំចិត្តឲ្យបរិសុទ្ធល្អ  ព្រោះរវល់ល្បក់តែទឹងធ្វើការងារ  មិនបានរែកជល់គំនិតអាក្រក់ផ្សេងៗ ។

ចំពោះអ្នកដែលមានភ្នែកបេះមើល  មានត្រចៀកបេះស្ដាប់  មានច្រមុះបេះស្រង់ក្លិន  រាល់ស្រែពុំមែនជាទស្សនភាពគួរឲ្យនឿយណាយធុញទ្រាន់នោះទេ  សឹងប្លែកៗ ពីរដូវមួយទៅរដូវមួយ  ពីពេលមួយទៅពេលមួយ  រដូវភ្ជួរ  ទាំងចាស់ទាំងក្មេងនាំគោនឹងនង្គ័លរបស់ខ្លួនទៅផ្ទៃដី  តាំងពីព្រលឹមរហូតដល់ថ្ងៃអស្តង្គត  បន្តគ្នាគួរឲ្យរមិលមើល ចាស់ៗ ហៅគោលួងលោមឲ្យដើរដោយស្រួល  ផាលចូកព្រះធរណីឲ្យត្រឡប់លើជាក្រោម  បែកខ្ចាយទៅជាអាចម៍បំណះធំ-តូច  ដឹកគន្ទងជាជួរពេញស្រែ  ក្មេងៗ ក៏ប្រណាំងគ្នាលេងសំដីចុះឡើងឆ្លើយឆ្លងគ្នា ព្ទុស្សូរតែចម្រៀងទឹងសព្វត្រដោកគ្រប់កន្ទែង ។  ឯអាកាសបក្សបក្សា ប្រឡែងផ្ទៀលឆ្ងាត់បន្ទឹចំរៀងពិរោះលន្ទោចលាន់ឮទៅឆ្ងាយ  នាំឲ្យអ្នកធ្វើការសប្បាយព្រឹចិត្តមានកំឡាំង ។

រដូវស្ទូង  ទាំងប្រុសទាំងស្រីងើបចុះងើបឡើងក្នុងស្រែរើកៗ ពីនេះទៅនោះរញៀវដូចស្រមោច  លុយទឹកប្រឹងៗ ប្អូនក៏សាចទឹកលើគ្នាលេង  ឯពួកនារីសោត  កាលបើវិលមកផ្ទះវិញមានមុខស្រម៉ក់ដោយភក់

ជាហេតុនាំឲ្យសុភិទ្រនឹកដល់កាព្យ "និរាសនគរវត្ត" របស់អ្នកឧកញ៉ា សុត្តន្តប្រីជា ឥន្ទ្រ ត្រង់បទថា:

" ស្តាយតែរូបនារីភងស្រីឡើ    ចុះស្ងួនស្រីត្រូវកំដៅព្រះសូរ្យា
និតទាំងដីភក់ហ្មងភក្ត្រា    អនិច្ចាជាតិអ្នកក្រីក្រជីវទោ ។
ចាស់ហើយតើនឹងតែងខ្លួនម្តេចល្អ    ប្រុសនឹងគិតថ្លៃទិញយល់តិចណាស់
ឃើញជាចុះថ្ងៃចោកល្មមប្រើប្រាស់    ការសង្វាសនឹងសង្វាតជាប់សង្កៀង ។

ធ្វើម្តេចនឹងបានពួកអ្នកស្រែចម្ការជាតិយើង បានថ្កុំថ្កើងស្តុកស្តម្ភឡើង នឹងបានដំកើងជីតាឲ្យនៅផ្ទះកុំឲ្យត្រូវកំដៅព្រះអាទិត្យ នឹងបញ្ចេញឲ្យទៅស្រែតែដល់រដូវច្រូត ពីព្រោះនៅខណៈនោះ ផ្ទៃដីក៏លុបបាត់ទៅនៅសល់តែគួរស្រូវលឿងធ្លុំធ្លៅដូចមាស នាំគ្នាកាន់កណ្តៀវទៅរំលំដើមស្រូវ ស្រែកច្រៀងយ៉ាងពីរោះពេញវាលស្រែ ទឹកសំឡេងមិនឡើងពេក មិនចុះហួសប្រមាណ សមនឹងភាពអ្នកស្រែនៅពេលនោះ ។

សុភិទ្រចំរើនវ័យបានអាយុ ១៥ ឆ្នាំហើយ បានរៀនធ្វើការខាងកសិកម្មគ្រប់មុខ ពេលថ្ងៃរះក៏ចេញពីផ្ទះទៅ ពេលថ្ងៃលិចក៏វិលមកផ្ទះវិញ ។ ល្ងាចមួយ ដើរមកដល់ផ្ទះនាងសាលី ក៏ស្ងាត់សូន្យពុំឃើញនាងឈរចាំផ្លូវដូចមុន ៗ ទៀត សុភិទ្រឆ្ងល់ណាស់ក៏ចូលទៅសាកសួរបានដំណឹងថា នាងទៅឯស្រុកភ្នំពេញបាត់ទៅហើយក៏នឹកមិនអស់ចិត្ត

ដោយនាងមិនបាននិយាយលាខ្លួនមួយម៉ាត់សោះ ស្រាប់តែទៅឥតស្រ-ណោះតែម្ដង បើបានដឹងផងគ្រាន់នឹងផ្ដាំឲ្យសួរកម្ដាយឲ្យផង ហើយនឹងបានផ្ញើជូនផ្ញើគ្នាតទៅគ្នាយមិនខ្វះ ទើបសុភិទ្រដំរង់ទៅផ្ទះជាទុក្ខមុខពុំសប្បាយ ។

ប្អូនថ្ងៃក្រោយមក សុភិទ្រកំពុងអង្គុយកាត់សក់ លោកឪពុកនាងសាលីទៅដល់ហុចសំបុត្រមួយច្បាប់ទៅឲ្យ អ្នកទទួលយកមកហើយ កើតរំភើបក្នុងចិត្តញ័រដៃកាន់សំបុត្រពុំចង់កើត បកស្រោមឡើងមើលសេចក្ដីថា :

> មកដល់សុភិន្ទ្រជាបង!
>
> "ពាក្យដំបូងរបស់ប្អូន គឺសូមបួងសួងទេវតាឲ្យជួយថែរក្សាបងឲ្យបានសេចក្ដីសុខ បានជាខ្ញុំមិនបានប្រាប់បងឲ្យដឹងនោះ ព្រោះខ្ញុំរវល់ណាស់ ត្រូវបង្ខំឲ្យទៅឯភ្នំពេញ យ៉ាងប្រញាប់ ម្ដាយមីងមានជម្ងឺឈឺជាទម្ងន់ ឥឡូវគាត់បានគ្រាន់បើហើយ ខ្ញុំនៅក្នុងទីនេះ ដូចជានៅឯណោះដែរ តែមានសេចក្ដីព្រួយជាខ្លាំង ដោយពុំបានឃើញមុខនឹងប្រស្រ័យជាមួយនឹងបង សេចក្ដីផ្ដាំផ្ញើងម្ដេចម្ដាបងមេត្តាអត់ទោសដល់ខ្ញុំផង ព្រោះជាគ្រាដំបូងដែលខ្ញុំសរសេរសំបុត្រ" ។
>
> ជាអ្នកប្អូនដែលនឹករលឹកមកបងជានិច្ច
>
> សាលី

សេចក្ដីសំបុត្រនេះ ដូចជាបោះអង្គើយពន់ពេកណាស់ មិនសមដល់អធ្យាស្រ័យប្អូនចិញ្ចឹមបេះដូង គឺនឹកអន់ចិត្តជន់ៗ តែមកនឹកថាប្រហែលជាខាងមិនប៉ិនខាងវិធីសរសេរសំបុត្រទេដឹង ទើបបានធូរទ្រូងបន្តិច ។

យប់នោះឯង ដោយអំណាចរលឹកប្អូនខ្លាំង សុកិន្ទ្ររសាប់រសល់ក្នុងចិត្តប្រែប្រួលចុះឡើងដេកពុំលក់ បេះតែឃើញរូបប្អូនជាប់នឹងភ្នែក គិតច្រើនពេកទៅនាំឲ្យក្ដៅក្បាល ហូតដល់ហូរឈាមតាមច្រមុះទទឹកខ្នើយដោក អស់កំឡាំងណាស់ខំប្រឹងក្រោកឡើង រកក្រមាជ្រលក់ទឹកយកមកគ្របលើថ្ងាស លុះត្រជាក់ក្បាលបានស្រួលដេកលក់ទៅ ដល់ពេលព្រឹកឡើង ទើបចាប់ដងប៉ាកកាសរសេរសំបុត្រតបទៅប្អូនវិញ មានសេចក្ដីថា:

កំពង់ធំថ្ងៃ ១៩ ខែណូវែម្ប្រឆ្នាំ ១៩៣៦.

## សាលីសំឡាញ់បង!

"បងមានសេចក្ដីត្រេកអរណាស់ នឹងបានទទួលសំបុត្ររបស់ប្អូនមួយច្បាប់ពីថ្ងៃម្សិលមិញ ព្រឹកនេះបងប្រញាប់ប្រញាប់តបមកវិញជូនប្អូន ដ្បិតស្រាប់ហើយរយៈឆ្ងាយណាស់ដែលយើងឃ្លាតពីគ្នា ការដែលបានសាសងជាមួយនឹងប្អូនតាមសំបុត្រនេះ ជាសេចក្ដីសប្បាយដល់បងពន្លឹក ហើយគ្រាន់នឹងបានធូរទ្រូងខ្លះ ពេលថ្ងៃនោះបងស្មានមើលទៅប្រហែលជាប្អូនកំពុងអង្គុយហាលខ្យល់ ប្រែងត្រចៀកចាំស្ដាប់ភាសារបស់បង ទេបងច្រឡំទេ! ប្រហែលជាប្អូនកំពុងប្រដាប់តក់ឲ្យម្ដាយមីង

របស់អូនទេនឹង? ឬមួយនាង...យ៉ាងណាបងក៏មិនប្រាកដ ព្រោះបងមើលទៅឃើញតែដោយមនោគតិប៉ុណ្ណោះ ម្ដេចក៏អូនឃ្លាតឆ្ងាយពីបងម៉្លេះ ឱសាលីអើយ! ហើយបងប្រាថ្នាតែនឹងនិយាយជាមួយនឹងប្អូនមាត់នឹងមាត់ប៉ុណ្ណោះ" ។

"ត្រង់ពាក្យប្អូនថា អូននៅឯណោះដូចនៅឯណេះដែរ, បងមិនអស់ចិត្តសោះ ហាក់ដូចជាអូនគ្មានសេចក្ដីស្រណោះដល់ស្រុកកំពង់ធំផងសោះ ដូចជាគ្មានរលឹកមកដល់បងបន្តិចបន្តួច ទេឬសាលីអើយ! ឬមួយអូនចង់ថាដូចម្ដេច?... អូនអើយបើអូនសម្រេចកិច្ចរួចហើយ ចូរប្អូនវិលមកវិញឲ្យឆាប់ណា កុំនៅយូរពេក អាណិតមកបងដែលសង្រេងសង្រែទាំងយប់ទាំងថ្ងៃមករកប្អូន ដែលបរិភោគបាយមិនឆ្ងាញ់ ដែលនិទ្រាពេលយប់បានតិចម៉ោងពេក ដែលមានចិត្តស្រពោនស្រពន់ពុំសប្បាយ មួយវិញទៀតបើអូនមានពេលទំនេរ ឲ្យអូនអាណិតស៊ើបសួរដំណឹងម្ដាយរបស់បងផង បងនឹងដឹងគុណប្អូនអស់មួយជីវិត" ។

"មុននឹងបញ្ចប់សំបុត្រនេះ បងសូមបញ្ជាក់សេចក្ដីថា រូបបងសព្វថ្ងៃនេះដូចជាទូកប្រាសចាកចង្កូត ពុំនោះសោត ដូចជាពិភពលោកប្រាសចាកពន្លឺព្រះអាទិត្យ ហេតុនេះសូមអូនអាណិតវិលមកឲ្យឆាប់ៗ ដើម្បីនឹងណែនាំនាវានោះឲ្យត្រង់តាមផ្លូវ ដើម្បីនឹងបំភ្លឺពិភពលោកឲ្យមានពន្លឺភ្លឺព្រោងព្រាយសប្បាយឡើង ។

*មកដល់ប្អូនដោយមេត្រីចិត្ត!*

សុភិន្ទ្រ

*លុះដល់ប្រាំថ្ងៃក្រោយមក សុភិន្ទ្របានដំណឹងថា នាងសាលីនឹងវិលមកផ្ទះវិញ ទើបបោលការងាររត់ទៅរង់ចាំឯស្ថានីយ៍រថយន្តឯណោះ មិនទាន់ដល់ម៉ោងក៏ត្រាស់ត្រាល់នៅមិននឹង ចង់បង្ខំព្រះអាទិត្យឲ្យនោះបរទៅឆាប់ៗ សាកសួរដំណឹងដល់អ្នកប្រចាំការជាច្រើនដង ទាល់តែគេធុញទ្រាន់មិនចង់និយាយរក ចុងបំផុតនាងក៏មកដល់ ។*

ដើរតាមផ្លូវមក   នាងក៏ហុចសំបុត្រមួយច្បាប់ប្រគល់ឲ្យទៅបង សុភិទ្របើកមើលដឹងសេចក្ដីគ្រប់សព្វហើយ   ធ្វើមុខជូរហាញគួរឲ្យអាណិតដាក់គូថចុះអង្គុយលើចំពោមចុល់ទង្គិះខ្សឹកខ្សួលជាច្រើន   សន្សឹមៗ ងើបមុខមើលប្អូនហើយនិយាយចេញមកថា 'កូនអើយ! បើបងគ្មានមួយសេនដូច្នេះ   តើនឹងទៅសួរអ្នកម្ដាយបងដូចម្ដេចបាន   ម្យ៉ាងទៀតឲ្យបងទៅតាមផ្លូវណា   មុខជាអ្នកឈឺធ្ងន់ណាស់ហើយមើលទៅ   ពុទ្ធោ! ពុទ្ធោអើយ!.... រួចក៏យំដូចជាកូនក្មេង ។

នាងសាលីទើបជួយគិតបងថា "ណ្ហើយបង   ប្អូនមាន៥៛០០ដែរ បងយកជាសោហ៊ុយទៅភ្នំពេញចុះ   បងដើរកាត់ព្រៃទៅ   រួចសឹមឡើងរថយន្តឯមុខឯណោះ   កុំឲ្យលោកពូលោកមីងជ្រាបឲ្យសោះ" ។

សុភិទ្រអរព្រួចខ្ញាតឡើងទៅលើផ្ទះស្លៀកពាក់ស្រួលបួល យកក្រមាវេចខោអាវព្រមទាំងបញ្ជីជាតិកំណើតសញ្ញាប័ត្រ   នឹងសំបុត្រស្នាមឯទៀតៗ   ទម្លាក់តាមបង្អួចទៅលើដើមផ្កា   រួចបានសរសេរសំបុត្រសូមទោសឪពុកដាក់លើតុក្នុងបន្ទប់របស់ខ្លួន   រួចក៏ចុះជណ្ដើរមួយៗ ថ្ងើយ៉ាងកំហ៊ី   សៀរៗ យកបង្អួចដើរបណ្ដើរក្រឡេកមើលក្រោយបណ្ដើរ ដល់ផុតផ្ទះហើយក៏តំរង់ទៅផ្ទះនាងសាលី   ទទួលយកប្រាក់ ៥៛,០០ ហើយលានាងចេញទៅ   សាកសួរផ្លូវដល់ចាស់ៗ ។

នាងសាលីឈរតាមមើលបងទាល់តែផុតកន្ទុយភ្នែក បានបែរងាកត្រឡប់ចូលទៅក្នុងផ្ទះវិញ មានទឹកភ្នែកស្រក់មុខ ។ (មានត)

# ច្បាប់ក្រមបរិយាយ

## លោកញុ៉ក ធូ គ្រូបង្រៀនជំនួយ

*នៅវិទ្យាល័យស៊ីសុវត្ថិ*

រៀបរៀង (តទៅ)

ទី ១ ៖ – ក្តីនេះជាច្បាប់ ឲ្យសាមណេរត្រាប់ សព្វ
សរិលទាំងឡាយ កុំសើចតិះដៀល អ្នកជាបាធ្យាយ
អ្នកហោងស្មើម្តាយ បង្កើតក្តីច្បាប់ ៗ

*បទវគ្គនេះជាច្បាប់ សំរាប់ដាស់តឿនសតិជនានុជនទាំងឡាយ ឲ្យបានសេចក្តីល្អ, បានជាលោកហាមឃាត់សាមណេរគ្រប់រូបថា "កុំសើចតិះដៀល អ្នកជាបាធ្យាយ អ្នកហោងស្មើម្តាយ បង្កើតក្តីច្បាប់" បានសេចក្តីថា គ្រូបាធ្យាយនេះ លោកជាអ្នកប្រដៅទូន្មាន ឲ្យចេះច្បាប់ទម្លាប់ទំនីមទំនៀម នឹងសេចក្តីខុសត្រូវគុណនឹងទោស ព្រមទាំងសិល្បសាស្ត្រ ចំណេះវិជ្ជាផ្សេងៗ ដោយហេតុនេះ ឃើញថាគ្រូបាធ្យាយ លោកមានគុណជាទម្ងន់ធ្ងន់ពន់ប្រមាណ ទុកស្មើដូចមាតា បានហាមឃាត់សិស្សានុសិស្ស ថាកុំឲ្យមើលងាយប្រមាថ តិះដៀល ឬនិយាយស្តីនូវពាក្យអសុរោះ ទ្រគោះប៉ោកប៉ោះ ឥតគួរសមទៅកាន់គ្រូបាធ្យាយឡើយ ៗ*

( ន័យគេថា )

សាមណេរណា ៗ នោះមានប្រាជ្ញា ដឹងចង់រៀន ច្បាប់ ឲ្យគាប់ត្រចៀក នោះដឹងចូលស្ដាប់ ធ្វើដោយ ក្រមច្បាប់ នៃគ្រូចាងហ្វាយ ៗ

បទនេះបានសេចក្ដីថា បើសិស្សឯណាមានប្រាជ្ញាឈ្លាសវៃ ហើយប្រាថ្នាចង់រៀននូវច្បាប់ទម្លាប់ដ៏ប្រសើរជាគ្រឿងប្រដាប់ ទុកសម្រាប់ខ្លួនប្រព្រឹត្តទៅ, នោះគប្បីប្រុងស្មារតីបញ្ញា គឺយកត្រចៀកប្រុងចាំស្ដាប់ពោលពាក្យអត្ថាធិប្បាយ ដែលគ្រូសំដែងប្រាប់ពន្យល់ដោយស្មោះ ពេលដែលកំពុងស្ដាប់នោះ ត្រូវតាំងចិត្តប្រុងស្មារតីប្រុងចាំស្ដាប់ចាប់យកអត្ថ-រសបទបាទមកតាមច្បាប់ទំនៀមទំនៀមតាំងអម្បាលម៉ាន កុំឲ្យមានចិត្តអណ្ដែតអណ្ដូងរាយមាយទៅកាន់អារម្មណ៍ដទៃ, ប្រយោជន៍កុំឲ្យខ្លួនចប់វេលាទៅទទេ ៗ តែឲ្យឆ្ងាយហើយ នោះពាក្យគ្រូពន្យល់តាំងប៉ុន្មាននឹងក្ដួចបាត់ខ្លះមិនលែង អ្នកនឹងខ្វះចំណេះដែលជាប្រដាប់សំរាប់ប្រើញ៉ាំងចរិយាខ្លួនជាគុណសម្បត្តិឲ្យល្អតទៅ ៗ

ទី ១២ – សាមណេរណាសោត ចិត្តពោះត្រេវត្រោន ឲ្យទៀសចេញឆ្ងាយ ច្បាប់នេះមិនចាំ សាមណេរនាំង-ឆ្ងាយ តាមចិត្តសប្បាយ អាត្មានីនៃ ៗ

អធិប្បាយថា ធម្មតាគ្រូអាចារ្យលោករមែងមានធម៌សង្គ្រោះដល់សិស្សគ្រប់រូប លោកតែងប្រដៅទូន្មាន តាមគន្លងធម្មចរិយា នឹងច្បាប់សំរាប់ប្រវេណី, តែពាក្យដែលពោលចេញមក ជួនកាលក៏ពីរោះ ជួនកាលក៏គំរាមកំហែងឲ្យខ្លាច, ទោះបីដូច្នោះត្រូវតែសិស្ស ទន់លំទោន ត្រងរង យកទុកដាក់ក្នុងចិត្តជាឡាក់ហាន តាមពាក្យលោកប្រដៅនោះ កុំឲ្យមានចិត្តក្រេវក្រោធប្រឡាតតបតទៅវិញ ឬមានចិត្តមនោមានះមិនប្រតិបត្តិតាម, នេះបើសិស្សណាជាមនុស្សប្រដៅក្រ នោះលោកពោលថា "ឲ្យចៀសចេញឆ្ងាយ" ទៅតាមអធ្យាស្រ័យរបស់ខ្លួនទីទៃៗតាមចិត្តសប្បាយចុះ លោកមិនបង្ខំទេ, ព្រោះលោកយល់ដូចន័យគាថានេះ ។

ឆរអ្នកគណា ដឹងដស្ទួដប្រាជ្ញា ឲ្យបានឆ្ងាយថ្ងៃ ចូរ
ដឹងខុសគាប់ ដោយអធ្យាស្រ័យ ផ្គាប់ដោយហឫទ័យ
អ្នកជាបាធ្យាយ ។

បទនេះបានសេចក្តីថា វិស័យអ្នកចង់ឲ្យបានខ្លួនមានដំណើរថ្កុំរុងរឿងមានកេរ្តិ៍ឈ្មោះ ត្រូវតែរករៀនវិជ្ជាសាស្ត្រទាំងឡាយផ្សេងៗ ឲ្យស្ទាញស្ទាត់ហ្មត់ចត់ បានជាលោកពោលថា "ចូរដឹងខុសគាប់" គឺឲ្យដឹងខុសនឹងត្រូវ ល្អនឹងអាក្រក់, ថ្លៃនឹងថោក ទាបនឹងខ្ពស់ ធំនឹងតូច ។ល។ ហើយឲ្យប្រព្រឹត្តប្រតិបត្តិតាមបែបក្បួនដែលគ្រូបិតាប្រៀនប្រដៅមក នេះទើបហៅថា "ផ្គាប់ដោយហឫទ័យ អ្នកជាបាធ្យាយ" ។

បើបានដូចពោលយ៉ាងនេះហើយ អ្នកនោះនឹងបានជាមនុស្ស មានដំនៀលមួយនឹងគេពុំលែងឡើយ ។

ទី ១៣.– ដោះជីងស្នែងធម៌ ឲ្យមានសំគាល់ កុំធ្វើភាយមាយ ដោះជីងស្នែងច្បាប់ កាន់ខ្ជាប់កុំបីណាយ កុំឲ្យអន្តរាយ ធ្វើច្បាប់ក្រោមជង ។

ឯពាក្យបទនេះ ត្រូវញែកជា ២ បទតាមទំនង –

បទទី ១ – "ដោះទីងស្នែងធម៌ ឲ្យមានសំគាល់ កុំធ្វើកយមាយ" បានសេចក្តីថា បើនរណាមានប្រាថ្នារកធម៌ ចង់រៀនធម៌, ត្រូវឲ្យមានសតិដំកល់មាំ សំគាល់ចាំទូកធម៌ទាំងនោះ ឲ្យជាក់ច្បាស់ ថានេះជាកងសុចរិត នេះជាកងទុច្ចរិត កុំធ្វើកយមាយផ្តេសផ្តាស កុំបណ្តែតបណ្តោយចិត្តឲ្យលៀនលយ ដ្រែលដ្រួស ឲ្យខុសហួសធម្មក្រិត្យា នឹងខូចប្រយោជន៍ដែលឲ្យកើតផល ។

ខនេះត្រូវឲ្យសិក្សា ឲ្យស្តាប់ធម៌ ១ ម៉ាត់នេះជាមុន តើអ្វីដែលហៅថាធម៌? "ធម៌" ប្រែថា សភាវៈដែលទ្រទ្រង់សត្វលោក គឺបានដល់បុណ្យកុសលសុចរិត ។ បើជា "អធម៌" វិញរមែងនាំសត្វឲ្យទៅកាន់ទុគ្គតិដោយចំណែកផ្សេង ៗ ។

លោកពោលថា ចំណែកបព្វជិតគឺភិក្ខុសាមណេរត្រូវប្រព្រឹត្ត

ប្រតិបត្តិធម៌ គឺសិក្ខាវិន័យឲ្យខ្ជាប់ខ្ជួនធ្វើខ្លួនឲ្យស្អាត ដោយសីល សមាធិបញ្ញាឲ្យផូរផង់ កុំឲ្យរំលងលើសល្មើសលើពុទ្ធតម្រាឡើយ ។

ចំណែកគ្រហស្ថបុរសស្ត្រី ដែលបានប្រកាសថ្វាយខ្លួនជាឧបាសកឧបាសិកា ជាអ្នករក្សាសីល៥សីល៨ ក៏ត្រូវដំកល់សីលនោះ ឲ្យបរិសុទ្ធផូរផង់ល្អ កុំឲ្យមានសៅហ្មង, គប្បីធ្វើឲ្យត្រឹមត្រូវតាមរបៀបពុទ្ធបញ្ញត្តិ ។

បទទី២– "គោរពនិងស្ងួនច្បាប់ កាន់ខ្ជាប់កុំបីណាយ កុំឲ្យអន្តរាយនូវច្បាប់ក្រមផង" បានសេចក្ដីថា បើនរជាតិជនឯណាមានសេចក្ដីសង្វាតរករៀនច្បាប់ម្ចាប់ទាំងពួងឲ្យបានចេះដឹង, លុះរៀនចេះដឹងហើយត្រូវប្រព្រឹត្តខ្លួនឲ្យត្រឹមត្រូវតាមវិធីច្បាប់ កាន់ខ្ជាប់ឲ្យមាំទាំ កុំឲ្យធ្វើឲ្យហួសច្បាប់ ដើម្បីរក្សាសេចក្ដីសុចរិត គឺមិនលុះដោយអគតិទាំង៤ មានឆន្ទាគតិជាដើម ។

ឯច្បាប់នោះ លោកញែកជា២ពួកផ្សេងគ្នាទៀត ពួកទី១.គឺច្បាប់ដែលម្ចាស់ផែនដី លោកបញ្ញត្តតែងតាំងទុកមក សំរាប់ផ្ដន្ទាទោសទណ្ឌកម្មមនុស្ស ដែលប្រព្រឹត្តល្មើសកន្លងរំលងព្រះរាជបញ្ញត្តិច្បាប់ត្រូវដាក់គុកឬពិន័យ តាមទោសានុទោស គឺមានច្បាប់ព្រហ្មទណ្ឌនិងច្បាប់រដ្ឋប្បវេណីជាដើម ។ ពួកទី២-គឺជាពាក្យបុរាណភាសិត ឬពាក្យគ្រូអាចារ្យ មាតាបិតាជាដើម ដែលលោកទូន្មានប្រដៅ មនុស្សប្រុសស្រី ឲ្យប្រព្រឹត្តប្រតិបត្តិដោយសុចរិតធម៌ ដើម្បីញ៉ាំងខ្លួនឲ្យល្អ

សុភាពរៀបរយ-សមរម្យតាមច្បាប់សំពប់ប្រពៃណី នោះគឺច្បាប់ក្រម,-កូនចៅ,-កេរ្តិ៍កាល,-ច្បាប់ស្រី,-ច្បាប់ប្រុស,-ច្បាប់ត្រីនេត្រ,-ច្បាប់ពាក្យចាស់, ។ល។ ជាប្រធាន ។ ច្បាប់ពួកនេះ បើនរជាតិជនណាមិនប្រព្រឹត្តតាមនឹងមានទណ្ឌកម្មផ្ទាទោសក៏ទេ គ្រាន់តែអំណោយផលឲ្យអ្នកនោះទៅជាមនុស្សថោកទាបអាប់អោនប្រាជ្ញា មិនជាទីរាប់អានជនានុជន, ព្រោះខ្លួនជាមនុស្សអន្ធពាលទៅហើយ ។

ន័យ ១ទៀត អ្នកឯណាពុំអាចប្រព្រឹត្តកាន់តាមច្បាប់ទាំងពីរជំពូកទុកបាន ក៏ព្រោះមកពីសេចក្តីប្រមាទនេះ ១, មកពីមិនក្រែងខ្លាចហើយល្មើសលើនេះ ២, មកពីមិនមានហិរិ គឺខ្មាសអៀនទីនឹងអំពើអាក្រក់និងឱត្តប្បៈ ខ្លាចក្រែងអំពើអាក្រក់នេះ ៣ ។

សេចក្តី ៣ ជំពូកនេះ នាំឲ្យមនុស្សឃ្លាតឃ្លៀងល្អៀងចេញមិនកាន់ច្បាប់ បើឃ្លាតពីច្បាប់ហើយ អ្នកនោះឯងពុំអាចនឹងធ្វើខ្លួនឲ្យបរិសុទ្ធតាមធម៌តាមច្បាប់បានឡើយ ។ នឹងមិនជាទីគោរពរាប់អានរបស់ជនានុជនបានឡើយ ព្រោះខ្លួនមិនប្រកាន់គោរពច្បាប់ឲ្យខ្ជាប់មាំមួនទៅហើយ, ធ្វើម្តេចឡើយនឹងនាំប្រដៅអ្នកឯទៀតបាន ។

ទី ១៤-ស្រីគ្រូចាញប្រាយ ប្រដូចផ្កាម្លាយ អាពុំគាបង
ហោង ហ៊ឺក្រញឹលប្រដៅ មិនឲ្យមានក្តង់ តាមៈដាយ
កង្វះ ព្រោងព្រឹទ្ធបុរាណ ។ (មាតត)

# សុវណ្ណសាមជាតក ពាក្យកាព្យ

## ព្រះសមុហ៍ឃោសាចារ្យ យូរ-ប៊ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

(តមកនឹងចប់)

ជនទាំងពីរនាក់នោះ ទូលចំពោះព្រះរាជា ថាខ្ញុំករុណា ព្រះអង្គជា
អ្នករក្សា ៗ សូមឲ្យតែព្រះអង្គ ជូនទៅត្រង់សាមបុត្រា អ្នកស្លាប់នៅ
ទីណា យើងយាត្រាទៅទីនោះ ៗ ស្តេចមានបន្ទូលថា កុំយាត្រាទៅឲ្យ
សោះ ទីនោះក្រែងមានគ្រោះ ត្រង់ចន្លោះព្រៃស្រោងស្រោង ៗ មាន
តែហ្វូងសត្វម្រឹគ ដោតតឹកចាំប្របខាង ស្កាត់ផ្លូវឲ្យគេងគាង ទឹងបៀស
ពាងទៅពុំរួច ៗ មានទាំងពួកស្វានស្វា ដំរីខ្លាប្លែកគ្រលួច ក្របីខ្ទឹង
ស្នែងស្រួច គួរព្រឺព្រួចសព្វអង្គា ៗ ពន្លឺព្រះអាទិត្យ អ័ព្ទងងឹតពេញ
មេឃា មិនគួរជនទ្រហោ ចរយាត្រាទៅបានឡើយ ៗ ឯជនទាំងពីរនាក់
ស្តាប់ឮជាក់ទុក្ខឥតស្បើយ អង្វរថាក្សត្រអើយ កុំគោះតើយស្ងៀមស្ងាត់
ទៅ ៗ បើទុកជាយ៉ាងណា សូមក្សត្រាជូនខ្ញុំទៅ ឲ្យបានដល់កូនពៅ
ទោះយប់ជ្រៅក៏មិនខាន ៗ បើមិនឃើញមុខកូន យើងស្លាប់សូន្យទាំង
ពីរប្រាណ ទឹងរស់នៅពុំបាន ទុក្ខក្តាហានខ្លាំងក្រៃលែង ៗ គ្រានោះ
ស្តេចបិលយក្ស នាំជនខ្វាក់ប្រាប់កន្លែង ដល់ហើយទើបទ្រង់ថ្លែង ថា
នេះឯងសាមបុត្រា ៗ ឯជនទាំងពីរនាក់ បានស្តាប់ជាក់កូនពុំងា

ដេកផ្ទាល់លើពសុធា ឥតមានគ្នានៅម្នាក់ឯង ៗ យកដៃស្ទាបបាតា ដល់សិរសាអើចម្បែង ខ្មោចផ្សាផ្ទន់ក្រៃលែង ហើយទើបថ្លែងរៀបរាប់ថា ៗ

## ពិលាបទុក្ខបណ្ឌិត និងនាងបារិកា

### ពាក្យ ៧

ឱសាមកុមារមុខស្រស់បោះ រូបល្អឥតខ្ចោះគួរគយគន់ សំដីនិយាយក៏ស្រទន់ ពីរោះពេកពន់ឥតឧបមា ៗ ឥឡូវមាតាបិតាមកឃើញកូនពន្ធកដល់មរណា ក្នុងទ្រូងស្ទើរប្រេះចេញពីគ្នា កើតទុក្ខវេទនាក្រៃអាល័យ ៗ កូនអើយអ្នកដូចជាស្រឹង ឬមួយកូនខឹងឥតអាស្រ័យ មាតាបិតាហើយលាក្ស័យ ទាំងនៅមានវ័យពេញសំឡាញ់ ៗ ឬមួយកូនព្រួយនឿយលំបាក បំពេកស្រាកហើយគ្មានខ្លាញ់ ទូលព្រះកជាទ្យលោកបាញ់ ឬកូនតាលតាញ់ព្រះបេស្តា ៗ ឱសាមកូនអើយអ្នកអកត្ញ យើងចាំងពីឆ្នាំទំពីងបា ចំណីភោជនទឹងផលា បានរស់ដ៏ក៏ព្រោះព្រលឹង ៗ ម្ដេចឡើយកូនស្លាប់ចោលយើងទៅ ឲ្យយើងរស់នៅឥតពំនឹង ពីថ្ងៃនេះហើយគ្មានទំពឹង ស្ងប់ស្ងាត់ស្ងួនឲ្យឈឺងដូចស្មសាន ៗ បើម្តាយឪពុកជាអៅក៏ ត្រាន់នឹងកេក្សាគ្នាទៅបាន ឥឡូវនឹងកចាំងពីរប៉ុណ្ណា ខ្ញុំម្តេចនឹងពឹងបានគ្នីគ្នា ៗ ស្តាយអើយស្តាយភាគកូនព្រលឹង មកដេកស្តូកស្តឹងក្នុងព្រៃក្សា ឆ្លើយដ៏ខ្សាច់ជាប់កាយា

មិនមានចោរតាមមកសោះ ៗ ឱលោកណាអើយនៅទីនេះ ដែលមានចំពោះជួយសង្គ្រោះ មេត្តាដល់ខ្ញុំដោយចិត្តស្មោះ ឲ្យកូនកំឡោះមានស្មារតី ៗ កាលកូនរស់នៅទីឧស្សាហ៍ ចរត្រាច់យាត្រារកចំណី ផ្លែឈើមើមឈើបេះថ្មីៗ ទាំងទុំចាស់ខ្ចីមិនខ្វះខាត ៗ ទឹកផ្លូតទឹកផឹកមានគ្រប់គ្រាន់ មិនឲ្យអស់ទាន់ទំសង្ខាត លុះពេលទៅដងព្រៃតាមខ្នាត សុខតែថាស្អាតពេញៗ ពាង ៗ ពេលព្រឹកអ្នកបោសទីអាស្រម ពេលថ្ងៃរៀបចំកោដន៍ស្អិតស្អាង ទាំងទឹកថ្ងៃយើងសងខាង ជានាអះអាងធ្វើសព្វគ្រប់ ៗ បើឥតពីកូនប្អូនទៅហើយ គ្មានអ្នកណាឡើយគេគោរព ធ្វើការទីនេះរាល់ថ្ងៃយប់ ល្មមនឹងសេពគប់ធ្វើជាគ្នា ៗ

## ពាក្យសម្ពះ បទព្រហ្មគីតិ

គ្រានោះជនពីរនាក់ បាត់ស្លូលពាក់សោកស្រណោះ ផ្គងដៃឡើងចំពោះ ក្នុងទីនោះសម្តាថា ៗ បើជាសាមបណ្ឌិត បានប្រព្រឹត្តនូវធម៌ណា ដោយសច្ចវាចា ពិសក្លៀវក្លាសាបសូន្យទៅ ៗ គឺមានចិត្តត្រេកអរ ប្រព្រឹត្តធម៌ដ៏ជ្រាលជ្រៅ ជាផ្លូវដែលកូនពៅ ដកល់នៅក្នុងចិន្តា ៗ ឬពោលនូវពាក្យពិត ពួកបណ្ឌិតហៅសត្យា ទីងបានថែរក្សា នូវមាតាបិតាផង ៗ ប្រព្រឹត្តធម៌កោតក្រែង ខ្លាចស្រប់ស្រែងចាស់រៀមច្បង មិនហ៊ានពោលកន្ទង ឲ្យសៅហ្មងដោយសំដី ៗ

ទាំងមានចិត្តស្នេហា ករុណាកូនពិសី ដោយគុណបុណ្យបារមី តិច ច្រើនក្តីជួយសង្គ្រោះ ៗ អ្នកប្រាជ្ញពីបុរាណ លោកតែងបានពោល ពីពេះ ថាសាមបណ្ឌិតនោះ កាន់ចំពោះធម៌ណាៗ ៗ សូមឲ្យបុណ្យ កុសល ជួយផ្តាច់ផល់ពិសក្តៀវក្លា ចេញចាកពីកាយា ដោយសច្ចធម៌នោះឯង ៗ

## ពាក្យនាងទេពធីតា

រីទេព្តាអង្គនោះ មកសង្គ្រោះហើយទើបថ្លែង សច្ចធម៌ជាក់ស្តែង ទឹងកន្លែងនោះទៀតថា ៗ ខ្ញុំបិតនៅទីនេះ យូរដល់ម៉េះឥតនណា ស្រឡាញ់ពេញចិត្តា ដូចជាបាសាមបណ្ឌិត ៗ ទាំងភ្នំគន្ធមាទន៍ បុរក្ខ ជាតិជាស័ក្តិសិទ្ធិ មានក្លិនក្រអូបពិត គួរពិចិត្របង់វេទនា ៗ ខ្ញុំពោល ពាក្យទាំងអស់ ជាសប្បុរសផ្សងសច្ចា សូមឲ្យពិសឈឺផ្សា ក្នុងសរីរ សាមបាត់ទៅ ៗ កាលបើជនទាំងនោះ ផ្គងចំពោះទឹកសំដៅ រកធម៌ ដែលមាននៅ គឺកូនពៅភ្ជាប់រក្សា ៗ រីឯសាមបណ្ឌិត បានប្រព្រឹត្ត ធម៌មេត្តា ដោយគុណបុណ្យសច្ចា មានសញ្ញាក្រោកឡើងហើយ ៗ ទើបក្រាបទៀបបាទា ពោលពាក្យថាឱម្ចាស់អើយ កូនបានរស់វិញ ហើយ កុំសោកឡើយចូរចរចា ៗ ទើបដឹកមកបង្គំ ស្តេចជាធំហើយ ទូលថា សូមយាងទៅសាលា ទាំងមាតាបិតាខ្ញុំ ៗ គ្រានោះពោធិសត្វ

បុរសគេចិត្តសុខុម មិនមានធម៌គំនុំ ប្រឹងបន្ទុំបុណ្យកុសល ។ ទើបនាំ
យកមាតា នឹងបិតាបានទៅដល់ ព្រមទាំងក្សត្រសោតសល់ ទីមណ្ឌល
នៃសាលា ។ រៀបចំទីបន្ទំ គួរនិយមដល់ក្សត្រា បំពេញធម៌មេត្តា
ដោយជ្រះថ្លាឥតសៅហ្មង ។ ហើយទូលថាព្រះអង្គ ស្តេចយាងត្រង់ទី
នេះមុន សូមទ្រង់មានបំណង ដោយប៉ុនប៉ងចង់សោយអ្វី ។ ផលា
ផងទាំងឡាយ ខ្ញុំលើកថ្វាយមានទុំខ្ចី ទ្រង់សោយដោយមេត្រី ទ្រង់កុំបី
ព្រួយព្រះទ័យ ។ ព្រះបាទបិលយក្ស ព្រះទ័យស្ញើគ្រអញ្ញាប្រិយ ទត
ឃើញហេតុបច្ច័យ ក្នុងសម័យគួរគោរព ។ ទើបមានបន្ទូលថា ខ្ញុំនេះ
ណាវង្វេងសិប មិនដឹងហេតុសព្វគ្រប់ ព្រោះដែលជាប់ដោយមោ-
ហា ។ បានឃើញអ្នកប្រាកដ ដល់កំណត់នឹងមរណា ឥឡូវមានជីវា
ដូចចន្ទ្រារះពេញវង់ ។ ទើបពោធិសត្វទូលថា បើអ្នកណាបានផ្គត់ផ្គង់
បំរើដោយផ្ចិតផ្ចង់ ចំពោះត្រង់ឪពុកម្តាយ ។ អ្នកនោះរួចពោសទុក្ខ
តទៅមុខបានវែងឆ្ងាយ ទេព្តាផងទាំងឡាយ ខំទ្រល់ថ្វាយជួយរក្សា ។
ទាំងពួកបណ្ឌិតផង តែងតាំងសរសើរថា ស្លាប់ទៅកើតសួគ៌ា ដោយ
ផលាការបំរើ ។ ស្តេចទ្រង់ព្រះសណ្តាប់ តបប្រញាប់ឆ្លើយថាអើ កិច្ច
នេះល្អណាស់តើ គួរអញធ្វើកុំបង្អង់ ។ ទើបផ្គងព្រះហត្ថា ត្រឹមសិរសា
បង្គំផ្គង់ ចិត្តស្មោះចំពោះត្រង់ ដល់តួអង្គពោធិសត្វ ។ ថាម្នាលសាម
បណ្ឌិត ខ្ញុំនេះពិតជាវិបត្តិ មិនដែលនឹកប្រយ័ត្ន កិច្ចប្រតិបត្តិដូរទីពឹង ។

សូមអ្នកពន្យល់ប្រាប់ ខ្ញុំចាំស្តាប់មិនទទឹង យកអ្នកជាទីពឹង គ្រាន់ពំនឹងដល់សាស្តា ៗ

## ពោធិសត្វសំដែងធម៌ ១០ ចំពោះស្តេចបិលយក្ស

គ្រានោះពោធិសត្វ បុរសរតនទ្រង់មេត្តា សំដែងធម៌ទេសនា ធម្មបរិយាទាំង ១០ យ៉ាង ៗ ចំពោះស្តេចបិលយក្ស ព្រះទ័យស្ងប់គ្រប់កសាង ទុកជាព្រែងសំណាង គ្រាន់និងអាងទៅខាងមុខ ៗ បពិត្រព្រះក្សត្រា ទីមួយណាទ្រង់ចាំទុក ចិញ្ចឹមម្តាយឪពុក ឲ្យបានសុខគ្រប់វេលា ៗ ទីពីរទ្រង់សន្តោស ប្រណីកោសបុត្រភរិយា សង្គ្រោះដោយទ្រព្យា ញ៉ាំងហាទយានឲ្យបានស្អាត ៗ ទីបីទ្រង់ប្រព្រឹត្ត ចំពោះមិត្រនិងអមាត្យ លៃលកត្រូវតាមខ្នាត ឲ្យនៅទបញ្ញាប់ផែនដី ៗ ទីបួនទ្រង់ទឹកដល់ អស់ពួកពលនិងពាជី សូមទ្រង់កុំញ៉ាំញី ផ្តាច់ជីវិតអស់សង្ខារ ៗ ទីប្រាំស្រែកទិតម ទ្រង់និយមច្បាប់ពជការ បើទ្រង់មានត្រូវការ យកពន្ធដារស្រាប្រណី ៗ ទីប្រាំមួយគឺរដ្ឋ និងជនបទធំឥតបី ការពារជនប្រុសស្រី ក្នុងដែនដីឲ្យបានសុខ ៗ ទីប្រាំពីររក្សា ធម៌សមណានិងព្រាហ្មណ៍ទុក ក្នុងអង្គជាប្រមុខ ទើបបានសុខស្រីសួស្តី ៗ ទីប្រាំបីមេត្តា ដោះប្រាណាម្រឹគបក្សី ទ្រង់កុំធ្វើបាបអ្វី ភ្ជាត់ស្លាប់ដល់មរណា ៗ ទីប្រាំបួនទ្រង់ធម៌ ដោយស្មោះសរប្រឹងសិក្សា រៀនសូត្រផ្លូវសាស្នា ទំការនាយកកុសល ៗ ទីដប់ទ្រង់

ប្រព្រឹត្ត ធម៌សុចរិតឥតកន្លង ជាផ្លូវនាំទៅដល់ ទីសកលឋានសួគ៌ា ៗ ពួកទេព្តាឥន្ទព្រហ្ម តែងនិយមយកផលា សទ្រាំគ្រប់ៗគ្នា ដោយជ្រះថ្លា ឥតសៅហ្មង ៗ បពិត្រព្រះមហាក្សត្រ ទ្រង់កំណត់ចិត្តចាំបង់ ធម៌ ១០ នេះឥតហ្មង កុំកន្លងហួសមាត្រា ៗ បើទ្រង់បានប្រព្រឹត្ត ឲ្យសុចរិតសព្វវេលា នឹងទៅកើតសួគ៌ា ឆកាមានោះពុំខាន ៗ ព្រះអង្គកុំប្រហែស ធម៌វិសេសដែលទ្រង់បាន ស្តាប់ចាំទាំងប៉ុន្មាន ទ្យអាក់ខានខូចអសារ ៗ មហាបុរសរតន៍ ញុំាងមហាក្សត្រឲ្យរក្សា សីលប្រាំពីបាណា ដល់សុរាទីបំផុត ៗ សូមទ្រង់តាំងសតិ ទឹងហាវិឲ្យបរិសុទ្ធ ដោយប្រាជ្ញាមោះមុត កុំតក់ស្លុតនឹងលោកធម៌ ៗ គ្រានោះស្តេចបិលយក្ស ព្រះទ័យស្ម័គ្រធម៌បវរ ទទួលដោយស្មោះសរ ទ្រង់ត្រេកអរឥតឧបមា ៗ ទ្រង់មានព្រះតម្រាស់ថាល្អណាស់អ្នកថ្លៃថ្លា ខ្ញុំដាក់លើសិរសា ជាសរណាមួយជីវិត ៗ ឥឡូវខ្ញុំសូមលា ទៅភពនឹងប្រព្រឹត្ត ធម៌នេះឲ្យសុចរិត តាមភាសិតដូចប្រាថ្នា ៗ បំណែកខាងឥសី នេះទាំងបីខំភាវនា សម្រេចអភិញ្ញា ទៅកើតនាឋានព្រហ្មលោក ៗ សត្ថាព្រះជាគ្រូ សព្វញ្ញូដ៏មានជោគ លះបោលគ្រឿងសោកគ្រោក បានវិមោក្ខគឺនិព្វាន ៗ សំដែងចង្អុលប្រាប់ តាមលំដាប់ជនដែលមាន ក្នុងកាលពីបុរាណ ឲ្យឃើញបានយ៉ាងនេះថា ៗ ព្រះឥន្ទ្រាធិរាជ មានអំណាចកាលនោះណា ឥឡូវបានមកជា អនុរុទ្ធជាអរហន្ត ៗ ព្រះបាទបិលយក្ស មានយសស័ក្តិធំលើសលុះ បានជាព្រះ

អានន្ទ អនុជតន់ព្រះជិនស្រី ។ ឯនាងបារិកា បានមកជានាងថេរី ភទ្ទកា-បិលានី ជាពួកស្រីមានសទ្ធា ។ នាងទេពធីតានោះ មានចិត្តស្មោះបានមកជា នាងឧប្បលវណ្ណា សាវិកាព្រះសម្ពុទ្ធ ។ ឯទុកូលបណ្ឌិត ឥសីសិទ្ធចិត្តបរិសុទ្ធ បានជាសិស្សព្រះពុទ្ធ ខ្ពស់បំផុតឈ្មោះកស្សប ។ សុវណ្ណ-សាមកុមារ បុណ្យអស្ចារ្យមិនត្រឡប់ មកកាន់ធម៌ជ្រាយផ្សព្វ តែងតែអប់រំចិត្តសត្វ ។ អន្ទោលជាតិមកត្រង់ ជាតួអង្គតថាគត បានត្រាស់ដឹងប្រាកដ គេកំណត់ថាព្រះពុទ្ធ ។ ទ្រង់ញុំាងពួកសព្វសត្វ ដែលវិបត្តិឲ្យរួចផុត ទៅកាន់ទីបរិសុទ្ធ លែងប្រគីនិញាន ។ រឿងនេះសូមសង្ខេប ធ្វើតាមបែបព្រះទ្រង់ញាណ ដែលបានទេសន៍ទូន្មាន ប្រោសប្រទានទុកជាច្បាប់ ។ ឲ្យយើងទាំងប្រុសស្រី ក្មេងចាស់ក្តីយកគម្រាប់ តាមផ្លូវលោកធ្វើស្រាប់ គួរតែគ្រាប់កុំលះបង់ ។ ទីបំផុតនេះខ្ញុំ សូមបង្គំចំពោះត្រង់ ព្រះពុទ្ធទ្រង់ស្រោចស្រង់ សត្វលិចលង់ក្នុងសង្សារ ។ និងធម៌បរិសុទ្ធ ខ្ពស់បំផុតពីរប្រការ ព្រះសង្ឃផ្តាច់សង្ខារ ខ្ញុំត្រូវការដោយគោរព ។ សូមឲ្យកំចាត់បង់ អពមង្គលសព្វគ្រប់ បានសុខទាំងថ្ងៃយប់ដោយគោរពគុណរតនា ។ សូមឲ្យមានកំឡាំង ចិត្តខ្ញុំតាំងផ្សងសទ្ធា បើបានកើតជាតិណា មានប្រាជ្ញាដ៏មោះមុត ។ បានកើតទាន់សាស្នា ខ្ញុំប្រាថ្នាជួបព្រះពុទ្ធ ស្តាប់ធម៌វិសេសសុទ្ធ ទីបំផុតនិញានហោង ។

ចប់សុវណ្ណសាមជាតក ទី ៣

# ពិធីព្រះរាជទានតាំងសមណស័ក្តិ

## ទីរាជាគណៈ– ចៅអធិការ– គ្រូសូត្រ

### នៅវត្តឧណ្ណាលោម

កាលពីថ្ងៃព្រហស្បតិ៍ ១៧ អ៊ូត ១៩៤៤ វេលាម៉ោង ១៧ និង ៣០ នាទី (ម៉ោង ៥ កន្លះល្ងាច) មានរៀបពិធីតាំងសមណស័ក្តិទីរាជាគណៈនិង ចៅអធិការ គ្រូសូត្រ ស្តាំ-ឆ្វេង ក្នុងវិហារវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងលោករេស៊ីដង់ស៊ុប៉េរីយើរនៃកម្ពុជរដ្ឋ ទ្រង់ស្តេចយាងទៅ-អញ្ជើញទៅ ជាអធិបតីក្នុងពិធីនេះ ជាផ្លូវរាជការព្រះករុណា និងរាជការអាណាព្យាបាល ។

លុះព្រះករុណាជាម្ចាស់ជីវិត និងលោករេស៊ីដង់ស៊ុប៉េរីយើរ ទ្រង់ស្តេចយាង-អញ្ជើញ ចូលក្នុងវិហារវត្តឧណ្ណាលោមហើយ ទ្រង់ប្រោសព្រះរាជទានប្រគេនសញ្ញាប័ត្រនិងផ្ចិតសមណស័ក្តិទីរាជាគណៈ ដល់ព្រះមហាថេរានុត្ថេរៈ ៩ រូប តាមលំដាប់ថ្នាក់មុនក្រោយ ។

១ – ព្រះពុទ្ធឃោសាចារ្យ (ជួន-ណាត) តាំងហ្វាងសាលាបាលីជាន់ខ្ពស់, រាជាគណៈសម្រាប់ទោ, បានឡើងសមណស័ក្តិជាព្រះពោធិវង្សរាជាគណៈ សម្រាប់ឯក ព្រមទាំងបានឡើងជាចៅអធិការវត្តឧណ្ណាលោមផង ។

២ – ព្រះសាក្យវង្ស (ហួត-តាត) អាចារ្យបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់, អធិបតីក្រុមជំនុំប្រែព្រះត្រៃបិដកនៅពុទ្ធសាសន-

បណ្ឌិត្យ, ក៏ជាគណៈសម្រាប់ត្រី, បានឡើងសមណស័ក្តិជា ព្រះមហាវិមលធម្ម (វឿនហ្វុង) ក៏ជាគណៈសម្រាប់ទោ ព្រមទាំងបានឡើងជាគ្រូសូត្រស្តាំវត្តឧណ្ណាលោមផង ។

៣.- ព្រះអរិយធម្មមុនី (វែន-ប៉ុល) ក៏ជាគណៈសម្រាប់ចត្វា, បានឡើងសមណស័ក្តិជា ព្រះសាក្យវង្ស ក៏ជាគណៈសម្រាប់ត្រី ។

៤ - ព្រះគ្រូឧត្តមមុនី (ម៉ឹង-សែស) ក្រុមជំនុំប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ បានឡើងសមណស័ក្តិជា ព្រះទេពមុនី ក៏ជា-គណៈសម្រាប់ចត្វា ព្រមទាំងបានឡើងជាគ្រូសូត្រឆ្វេងវត្តឧណ្ណាលោមផង ។

៥ - ព្រះបាឡាត់អរិយវិមល (ពៅ-នេត្រ) បានឡើងសមណ-ស័ក្តិជា ព្រះឥន្ទមុនី ក៏ជាគណៈសម្រាប់ចត្វា ។

៦ - ព្រះគ្រូវិមលបញ្ញា (យយ-ហ៊ូ) បានឡើងសមណស័ក្តិជា ព្រះធម្មវិបស្សនា ក៏ជាគណៈសម្រាប់ចត្វា ។

៧ - ព្រះបាឡាត់ពោធិកម (នួន-គិ) បានឡើងសមណស័ក្តិជា ព្រះសិរីសុមង្គលញាណ ក៏ជាគណៈសម្រាប់ចត្វា ។

ព្រះក៏ជាគណៈទាំង ៧ រូបនេះ គង់នៅវត្តឧណ្ណាលោម ។

៨ - ព្រះគ្រូបរិយបិដក (ពៅ-ញាណ) បានឡើងសមណស័ក្តិជា ព្រះធម្មវិសុទ្ធិវង្ស ក៏ជាគណៈសម្រាប់ចត្វា ។

៩ - ព្រះគ្រូវជិតសត្ថា (ផង់-កុយ) បានឡើងសមណសក្តិជាព្រះញាណសំវរ ពជាគណៈសម្រាប់ចត្វា ។

ព្រះពជាគណៈទាំង ២ រូបនេះ គង់នៅវត្តសារាវ័ន ។

លុះរួចកិច្ចព្រះពជទានសញ្ញាប័ត្រនិងផ្ទិតសមណសក្តិស្រេចហើយ ទើបព្រះមហាវិមលធម្ម (ហួត-តាត) សូត្រសុទ្ធរកថា ជាតំណាងតាងនាមនៃព្រះមហាថេរានុត្ថេរៈ ដែលបានទទួលសមណសក្តិថ្មី ព្រមទាំងសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយនិងព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ នូវអស់ព្រះសង្ឃថេរានុត្ថេរៈទាំងឡាយជាង ១០០ រូប ដែលបាននិមន្តមកកាន់ទីសន្និបាតនោះ ។

លុះចប់សុទ្ធរកថាហើយ ព្រះសង្ឃទាំងអស់ក្នុងទីសន្និបាតនោះបានសូត្រធម៌ "ជយន្តោ" ចំរើនសិរីសួស្តីជយមង្គល ថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង, ជូនលោកឡឺរេស៊ីដង់ត៍ស៊ុប៉េរីយ៉េរ និងអស់លោករដ្ឋមន្ត្រីសេនាបតី ។

លុះចប់ធម៌ជយន្តោហើយ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់កាន់ផ្ចុងផ្កា ១ កម្រង លោកឡឺរេស៊ីដង់ត៍ស៊ុប៉េរីយ៉េរកាន់ផ្ចុងផ្កា ១ កម្រង ស្តេចអញ្ជើញយកទៅដាក់ថ្វាយក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូប ។ ព្រះពោធិវង្ស (ជួន-ណាត) បានថ្វាយទៀនធំ ១ ចំពោះព្រះករុណាជាម្ចាស់ជីវិត, ទៀនធំ ១ ទៀតជូនទៅលោកឡឺរេស៊ីដង់ត៍ស៊ុប៉េរីយ៉េរ ហើយ

បានអុជបូជាព្រះរតនត្រ័យ ៗ ព្រះពោធិវ័ង្ស បានធ្វើសច្ចាធិដ្ឋានចំពោះព្រះភ័ក្ត្រព្រះករុណាជាម្ចាស់ជីវិត មានលោកឡឺរេស៊ីដង់ស៊ុបេរីយើរ ប៉ិតនៅក្នុងទីនោះផងថា សូមឲ្យកម្ពុជរដ្ឋរួចផុតចាកគ្រោះថ្នាក់គ្រប់យ៉ាង! សូមឲ្យចួបប្រទះតែសេចក្ដីសុខសេចក្ដីចំរើនតរៀងទៅ!

ព្រះករុណាជាម្ចាស់ជីវិតនិងលោកឡឺរេស៊ីដង់ស៊ុបេរីយើរ ក៏សំ-ដែងសេចក្ដីរីករាយទទួលពាក្យសច្ចាធិដ្ឋានរបស់ព្រះពោធិវ័ង្ស ៗ

ពួកឧបាសកជើងវត្តឧណ្ណាលោម បានលៀងភេសជ្ជៈចំពោះអស់លោកភ្ញៀវដែលក្នុងឧកាសនោះ ដោយសោមនស្សរីករាយនិងគារ-វភាព ៗ

មួយទៀត ក្នុងពិធីនោះ មានពុទ្ធសាសនិកបព្វជិតគ្រហស្ថ ដែលនិមន្តមក - អញ្ជើញមកជួបជុំជាច្រើន ៗ ខាងបព្វជិត មានសម្ដេចព្រះមហាសុមេធាធិបតីជាប្រធាន ៗ ខាងគ្រហស្ថ (ក្រៅពីព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងលោកឡឺរេស៊ីដង់ស៊ុបេរីយើរ) មានលោកអ្នកឧកញ៉ាអគ្គមហាសេនាជាដើម ៗ ខាងក្រសួងពុទ្ធសា-សនបណ្ឌិត្យ មានលោកអគ្គលេខាធិការ ឌុយប៉ុង ជាដើម ៗ ចំណែកខាងពួកឧបាសកជើងវត្តឧណ្ណាលោម មានអ្នកឧក្រស៊ីញេកជាដើម បានមកជួបជុំប្រគេនភេសជ្ជៈ ដល់ព្រះសង្ឃជាសាធារណទានមិនចំពោះបុគ្គល, ភេសជ្ជទាននោះច្រើនបរិបូណ៌ ឥតមានខ្វះខាតឡើយ ៗ

## មច្ឆាកុភជជាតក

## អាចារ្យ គី-គឹមស៊ុវ ប្រែនិងរៀបរៀង

យាវតា ចក្ខុមស្សរិយាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ ឧក្កណ្ឋិតភិក្ខុំ អារព្ភ កថេសិ ។

សត្ថា រីអង្គសម្តេចព្រះបរមសាស្តាចារ្យវង្ស កាលស្តេចទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថ កំណត់នៅក្នុងព្រះវិហារជេតពនសុគន្ធកុដីស្រីមហាវិហារ អារព្ភ ទ្រង់ព្រះប្រារព្ធភិក្ខុអ្នកអផ្សុកមួយរូបឲ្យជាហេតុ កថេសិ ទើបទ្រង់សំដែងជាតកនេះដោយគាថាថា យាវតា ចក្ខុមស្សរិយា ដូច្នេះជាដើម ។

ការ ដូចបានឮមកថាមានភិក្ខុ ១ រូបត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី បានឃើញស្ត្រីមានកាយប្រដាប់ដោយគ្រឿងអលង្ការ ក៏កើតសេចក្តីបដិព័ទ្ធក្នុងស្ត្រីនោះ ហើយមានសេចក្តីអផ្សុកប្រាថ្នានឹងសឹកចេញជាឃរាវាស ភិក្ខុទាំងឡាយដឹងរឿងនោះ ទើបនាំភិក្ខុនោះទៅគាល់សម្តេចព្រះលោកនាថហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះជាអ្នកមានសេចក្តីអផ្សុក ។

សម្តេចព្រះបរមសាស្តាមានព្រះពុទ្ធត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកមានសេចក្តីអផ្សុកពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គអផ្សុកពិតមែន ទើបមានព្រះពុទ្ធត្រាស់ថា

ម្នាលភិក្ខុ បើអ្នកសឹកចេញទៅជាឃរាវាស អ្នកនឹងអាចញ៉ាំងសេចក្តីប្រាថ្នាឲ្យពេញបានដែរឬ? ធម្មតាតណ្ហា គឺសេចក្តីប្រាថ្នាក្នុងកាមគុណទាំង ៥ នេះជារបស់ដែលបុគ្គលណាមួយមិនគប្បីឲ្យពេញបាន ប្រៀបដូចមហាសមុទ្រដ៏ធំទូលាយមិនអាចនឹងឲ្យពេញដោយទឹកដែលហូរមកអំពីមហានទីទាំង ៥ ដូច្នោះ សូម្បីបុរាណបណ្ឌិតទាំងឡាយ ដែលបានសោយសិរីរាជសម្បត្តិជាបរមចក្រពត្រាធិរាជ មានអំណាចផ្សាយទៅក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ នឹងបានសោយទិព្វសួគ៌ក្នុងជាន់ចាតុម្មហារាជិកា ទាំងបានសោយទិព្វសម្បត្តិក្នុងតាវត្តិង្សទេវ-លោកឋិតនៅក្នុងវិមានសម្តេចសក្កទេវរាជអស់កាលយូរ រហូតសម្តេចមឃក់កន្លងទៅដល់ ៣៦ ព្រះអង្គ ក៏នៅតែមិនអាចញ៉ាំងកាមតណ្ហាគឺសេចក្តីប្រាថ្នាក្នុងកាមគុណទាំង ៥ ឲ្យបរិបូណ៌ពេញទីបាន ម្នាលភិក្ខុ អ្នកអាចនឹងធ្វើកាមតណ្ហា ឲ្យបរិបូណ៌ពេញទីបានដែរឬ? កាលមានព្រះពុទ្ធត្រាស់ដូច្នេះហើយ ទើបទ្រង់នាំរឿងក្នុងអតីតកាលមកត្រាស់ទេសនាដូចតទៅនេះ ៗ

អតីតេ បឋមកប្បេ មហាសម្មតោ នាម រាជា អហោសិ ៗ

ក្នុងកាលបឋមកប្បកន្លងទៅហើយ មានព្រះរាជាមហាសម្មតិវង្ស ១ ព្រះអង្គ ព្រះរាជឱរសរបស់ព្រះរាជាអង្គនោះ បានជាក្សត្រទ្រង់

ព្រះនាមថា ព្រះចៅរោជរាជ ព្រះរាជឱរសរបស់ព្រះចៅរោជរាជនោះ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះចៅវររោជរាជ ព្រះរាជឱរសរបស់ព្រះចៅវររោជរាជនោះបានជាក្សត្រទ្រង់ព្រះនាមថា ព្រះចៅកល្យាណបតី ព្រះរាជឱរសរបស់ព្រះចៅកល្យាណបតីនោះ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះចៅឧបោសថរាជ ព្រះរាជឱរសរបស់ព្រះចៅឧបោសថរាជនោះ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះចៅវរឧបោសថ ព្រះរាជឱរសរបស់ព្រះចៅវរឧបោសថរាជនោះ បានជាក្សត្រិយ៍ទ្រង់ព្រះនាមថា ព្រះចៅមន្ធាតុរាជ ព្រះចៅមន្ធាតុរាជនោះប្រកបដោយរាជរិទ្ធិសក្តាតេជះបរិបូណ៌ដោយរតនពិសេស ៧ ប្រការ ជាបរមចក្រពត្រាធិរាជ មានបុញ្ញានុភាពអស្ចារ្យក្នុងកាលដែលព្រះអង្គទ្រង់បក់ព្រះហស្តខាងឆ្វេង ស្ទាបព្រះហស្តខាងស្តាំ ភ្លៀងកែវ ៧ ប្រការក៏បង្អុរចុះមកប្រមាណត្រឹមជានុមណ្ឌល ដូចជាភ្លៀងបង្អុរធ្លាក់ចុះមកអំពីអាកាស ព្រះចៅមន្ធាតុរាជជាមនុស្សអស្ចារ្យយ៉ាងនេះ កាលព្រះអង្គទ្រង់វ័យនៅជាកុមារប្រកបដោយការលេង កំណត់កាលដ៏យូរបាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ កាលបានសោយសិរីរាជសម្បត្តិជាបរមចក្រពត្រាធិរាជ កំណត់កាលបាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ ព្រះជន្មាយុរបស់ព្រះចៅមន្ធាតុរាជនោះមានកំណត់បាន ១ អសង្ខេយ្យ ។

លុះតមកមានមួយថ្ងៃ ព្រះចៅមន្ធាតុបរមចក្រពត្រាធិរាជនោះ មិនអាចនឹងញ៉ាំងកាមតណ្ហាឲ្យល្មមព្រះទ័យបាន ទើបទ្រង់សំដែងអាការដែលព្រះអង្គទ្រង់អផ្សុក គឺមិនត្រេកអរក្នុងរាជសម្បត្តិ ។ ពួកអាមាត្យរាជបរិស័ទក្រាបបង្គំទូលសួរថា: បពិត្រព្រះអង្គជាសម្មតិទេវរាជ អាការដែលព្រះអង្គទ្រង់អផ្សុកនោះ បណ្ដាលមកអំពីហេតុអ្វី? នែ! អាមាត្យទាំងឡាយ យើងឃើញកំឡាំងបុណ្យរបស់យើងមានច្រើន សិរីរាជ-សម្បត្តិប៉ុណ្ណោះមិនល្មមដល់សេចក្ដីត្រេកអររបស់យើងទេ សិរីរាជ-សម្បត្តិក្នុងឋានណាហ្ន៎ ទើបជាទីរីករាយជាងនេះ? បពិត្រព្រះអង្គជាសម្មតិទេវរាជ ទេវលោក ទើបជាទីរម្មណីយដ្ឋាន សម្រាន្តព្រះទ័យជាងមនុស្សលោកនេះ ។ ព្រះចៅមន្ធាតុបរមចក្រពត្តិ បានទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ក៏ទ្រង់ធ្វើចក្រកែវឲ្យនាំទៅក្នុងខាងមុខ ហើយស្ដេចយាត្រាព្រមដោយរាជបរិស័ទតាមចក្រកែវនោះឡើងទៅកាន់អា-កាសវិថី ។

ចំណែកស្ដេចចាតុម្មហារាជិកាទាំង ៤ ឃើញព្រះចៅមន្ធាតុបរម-ចក្រពត្តិ ស្ដេចមកក៏កាន់ទិព្យមាលា មានគ្រឿងក្រអូបឈ្មុយឈ្ងប់ នាំពួកទេពធីតាទាំងឡាយជាបរិវារមកធ្វើបច្ចុគ្គមនាការនៅពាក់កណ្ដាលមាគ៌ា អញ្ជើញស្ដេចៈឡើងទៅប្រថាប់ក្នុងឋានចាតុម្មហារាជិកា ហើយក៏បង្វែរសិរីសម្បត្តិក្នុងឋានចាតុម្មហារាជិកាថ្វាយព្រះចៅមន្ធាតុបរមចក្រពត្តិ សូម្បី

បានសោយទិព្វសម្បត្តិក្នុងជាន់ចាតុម្មហារាជិកា ព្រមដោយពពួកបរិស័ទ នឹងទេវបរិស័ទអស់កាលយូរ ក៏នៅមិនអាចនឹងធ្វើសេចក្តីប្រាថ្នាឲ្យពេញបាន ទើបសំដែងអាការដែលព្រះអង្គទ្រង់អផ្សុកទ្រង់មិនបានត្រេកអរក្នុងទេវសម្បត្តិក្នុងជាន់ចាតុម្មហារាជិកានោះទៀត ។ សម្តេចចាតុម្មហារាជិកាទាំង ៤ ក៏ក្រាបបង្គំទូលសួរថា បពិត្រមហារាជព្រះអង្គទ្រង់អផ្សុកដោយហេតុអ្វី? ព្រះចៅមន្ធាតុបរមចក្រពត្តិត្រាស់ថា សិរីសម្បត្តិត្រឹមប៉ុណ្ណេះនៅមិនជាទីត្រេកអរល្មមដល់សេចក្តីប្រាថ្នារបស់យើងទេ ហើយត្រាស់សួរថា សិរីសម្បត្តិក្នុងទីណាហ្ន៎ ទើបជាទីត្រេកអរវិសេសជាងនេះទៀត? សម្តេចចាតុម្មហារាជិកាទាំង ៤ ក្រាបបង្គំទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គទាំងឡាយនេះជាអ្នកទទួលធ្វើការក្រោមបង្គាប់ស្តេចនៃទេវតាទេ ទីដែលរម្មណីយដ្ឋានជាងគេនោះមានតែតាវត្តិង្សទេវលោកឯណោះ ទើបជាទីរីករាយទៅដោយកាមារម្មណ៍ដ៏ឧត្តមជាងជាន់ចាតុម្មហារាជិកានេះ ។ កាលព្រះចៅមន្ធាតុបរមចក្រពត្តិ បានទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ទើបទ្រង់ធ្វើចក្ករតនឲ្យនាំទៅក្នុងខាងមុខ ព្រះអង្គព្រមដោយពពួកបរិស័ទ ក៏ស្តេចបែរព្រះភក្ត្រចំពោះទៅតាវត្តិង្សទេវលោក ។

លំដាប់នោះសម្តេចសក្កទេវរាជ ទតព្រះនេត្រឃើញព្រះចៅមន្ធាតុបរមចក្រពត្តិស្តេចមក ទើបទ្រង់កាន់ទិព្វមាលាសុគន្ធជាតិ មានអម្ពរ

ទេវតាចោមរោមជាបរិវារ ស្ដេចចេញទៅធ្វើបច្ចុគ្គមនាការទទួលចាប់ព្រះហស្ដព្រះចៅមន្ធាតុបរមចក្រពត្តិហើយត្រាស់ថា សូមអញ្ជើញស្ដេចយាងមកខាងណេះ លុះព្រះចៅមន្ធាតុរាជស្ដេចទៅដល់សំណាក់សម្ដេចមឃវាហើយ ពួករតនបរិនាយកពលកែវក៏នាំចក្រកែវព្រមទាំងរាជបរិស័ទត្រឡប់ចុះមកកាន់មនុស្សលោកវិញ ចំណែកសម្ដេចមឃវាទេវរាជនោះ លុះនាំព្រះចៅមន្ធាតុបរមចក្រពត្តិមកដល់តាវត្តិង្សទេវភពហើយ ក៏បែងចែកទិព្វសម្បត្តិថ្វាយព្រះចៅមន្ធាតុ បរមចក្រពត្តិនោះពាក់កណ្ដាលហើយឲ្យប្រថាប់នៅក្នុងតាវត្តិង្សទេវនគរ ។

ចាប់ដើមអំពីនោះមក ព្រះរាជាទាំងពីរព្រះអង្គគឺព្រះចៅមន្ធាតុបរម-ចក្រពត្តិនិងសម្ដេចកោសិយសក្កទេវរាជក៏សោយទិព្វសម្បត្តិរដ្ឋសុខស្មើគ្នាក្នុងតាវត្តិង្សទេវភពនោះកំណត់កាលបាន ៣ កោដិ ៦០ សែនឆ្នាំ លុះសម្ដេចព្រះកោសិយសក្កទេវរាជអង្គនោះអស់ព្រះជន្មាយុចុតិទៅ សម្ដេចសក្កទេវរាជអង្គថ្មីមកឧប្បត្តិជំនួសឡើងទៀត ហើយសោយរដ្ឋសុខពាក់កណ្ដាលដូចអង្គមុន កាលបើដល់អាយុក្ស័យហើយក៏ចុតិទៅ សក្កទេវរាជដែលឧប្បត្តិឡើងនិងចុតិទៅវិញដោយទំនងនេះ រាប់បាន ៣៦ ព្រះអង្គ ចំណែកព្រះចៅមន្ធាតុបរមចក្រពត្តិនោះ មានព្រះសរីរកាយជាមនុស្សបានសោយទិព្វសុធាភោជន៍ដ៏បរិសុទ្ធទើបមិនចុតិចាកទេវស្ថាន ។

បានសោយទិព្វសម្បត្តិក្នុងឋានចាតុម្មហារាជិកា ព្រមដោយពពួកបរិស័ទ ទាំងទេវបរិស័ទអស់កាលយូរ ក៏នៅមិនអាចនឹងធ្វើសេចក្ដីប្រាថ្នាឲ្យពេញបាន ទើបសំដែងអាការដែលព្រះអង្គទ្រង់អផ្សុកទ្រង់មិនបានត្រេកអរក្នុងទេវសម្បត្តិក្នុងឋានចាតុម្មហារាជិកានោះទៀត ។ សម្ដេចចាតុម្មហា-រាជិកាទាំង ៤ ក៏ក្រាបបង្គំទូលសួរថា បពិត្រមហារាជព្រះអង្គទ្រង់អផ្សុកដោយហេតុអ្វី? ព្រះចៅមន្ធាតុបរមចក្រពត្តិត្រាស់ថា សិរីសម្បត្តិត្រឹមប៉ុណ្ណេះនៅមិនជាទីត្រេកអរល្មមដល់សេចក្ដីប្រាថ្នារបស់យើងទេ ហើយត្រាស់សួរថា សិរីសម្បត្តិក្នុងទីណាហ្ន៎ ទើបជាទីត្រេកអរវិសេសជាងនេះទៀត? សម្ដេចចាតុម្មហារាជិកាទាំង ៤ ក្រាបបង្គំទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គទាំងឡាយនេះជាអ្នកទទួលធ្វើការក្រោមបង្គាប់ស្ដេចនៃទេវតាទេ ទីដែលរម្មណីយដ្ឋានជាងគេនោះមានតែតាវត្តិង្សទេវលោកឯណោះ ទើបជាទីរីករាយទៅដោយកាមារម្មណ៍ដ៏ឧត្តមជាងឋានចាតុម្ម-ហារាជិកានេះ ។ កាលព្រះចៅមន្ធាតុបរមចក្រពត្តិ បានទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ទើបទ្រង់ធ្វើចក្រកែវឲ្យនាំទៅក្នុងខាងមុខ ព្រះអង្គព្រមដោយពពួកបរិស័ទ ក៏ស្ដេចហើរព្រះកក្រុចំពោះទៅតាវត្តិង្ស-ទេវលោក ។

លំដាប់នោះសម្ដេចសក្កទេវរាជ ទតព្រះនេត្រឃើញព្រះចៅមន្ធា-តុបរមចក្រពត្តិស្ដេចមក ទើបទ្រង់កាន់ទិព្វមាលាសុគន្ធជាតិ មានអមរ

ទេវតាចោមរោមជាបរិវារ ស្តេចចេញទៅធ្វើបច្ចុគ្គមនាការទទួលចាប់ព្រះហស្តព្រះចៅមន្ធាតុបរមចក្រពត្តិហើយត្រាស់ថា សូមអញ្ជើញស្តេចយាងមកខាងណេះ លុះព្រះចៅមន្ធាតុរាជស្តេចទៅដល់សំណាក់សម្តេចមឃវាហើយ ពួករតនបរិនាយកពលកែវក៏នាំចក្រកែវព្រមទាំងរាជបរិស័ទត្រឡប់ចុះមកកាន់មនុស្សលោកវិញ ចំណែកសម្តេចមឃវាទេវរាជនោះ លុះនាំព្រះចៅមន្ធាតុបរមចក្រពត្តិមកដល់តាវត្តិង្សទេវភពហើយ ក៏ចែងទិព្វសម្បត្តិថ្វាយព្រះចៅមន្ធាតុ បរមចក្រពត្តិនោះពាក់កណ្តាលហើយឲ្យប្រថាប់នៅក្នុងតាវត្តិង្សទេវនគរ ។

តាំងពីដើមអំពីនោះមក ព្រះរាជាទាំងពីរព្រះអង្គគឺព្រះចៅមន្ធាតុបរមចក្រពត្តិនិងសម្តេចកោសិយសក្កទេវរាជក៏សោយទិព្វសម្បត្តិរួមសុខស្មើគ្នាក្នុងតាវត្តិង្សទេវភពនោះកំណត់កាលបាន ៣ កោដិ ៦០ សែនឆ្នាំ លុះសម្តេចព្រះកោសិយសក្កទេវរាជអង្គនោះអស់ព្រះជន្មាយុចុតិទៅ សម្តេចសក្កទេវរាជអង្គថ្មីមកឧប្បត្តិជំនួសឡើងទៀត ហើយសោយរួមសុខពាក់កណ្តាលដូចអង្គមុន កាលបើដល់អាយុក្ស័យហើយក៏ចុតិទៅ សក្កទេវរាជដែលឧប្បត្តិឡើងនឹងចុតិទៅវិញដោយទំនងនេះ រាប់បាន ៣៦ ព្រះអង្គចំណែកព្រះចៅមន្ធាតុបរមចក្រពត្តិនោះ មានព្រះសរីរកាយជាមនុស្សបានសោយទិព្វសុខាភោគន៍ដ៏បរិសុទ្ធទើបមិនចុតិចាកទេវស្ថាន ។

លុះដល់សម្តេចសក្កទេវរាជអង្គទី ៣៦ ច្យុតិទៀងក្នុងតាវត្តិង្សទេវភពទៀត ក៏បានសោយទិព្វសម្បត្តិរដ្ឋសុខពាក់កណ្តាលដូចអង្គមុនៗ ឯព្រះចៅមន្ធាតុបរមចក្រពត្តិមានសេចក្តីប្រាថ្នាក្នុងបញ្ចពិធកាមគុណមិនមានទីបំផុត ក៏កើតសេចក្តីខ្វល់ខ្វាយចិត្តមិនគាប់ព្រះទ័យក្នុងរដ្ឋសុខត្រឹមប៉ុណ្ណោះ ទើបទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដែលយើងមកសោយទិព្វសម្បត្តិតែត្រឹមពាក់កណ្តាលប៉ុណ្ណោះ យើងនឹងផ្តាច់ព្រះជន្មជីពសម្តេចមឃវាអង្គនេះចេញ ហើយនឹងសោយទិព្វសម្បត្តិក្នុងជាន់តាវត្តិង្សនេះឲ្យជាបរមសុខតែម្នាក់ឯង, តែទ្រង់មិនអាចនឹងផ្តាច់ព្រះជន្មជីពសម្តេចមឃវានោះបានឡើយ កាលបើមិនសម្រេចព្រះរាជបំណងដូចទ្រង់ព្រះតម្រិះទុក ក៏កើតទុក្ខទោមនស្សតូចព្រះទ័យគ្រប់ទិវារាត្រី ។

ធម្មតាកាមតណ្ហា គឺសេចក្តីប្រាថ្នាក្នុងកាមគុណនេះ ជាមូលនៃសេចក្តីវិបត្តិ ព្រោះហេតុនោះ អាយុសង្ខាររបស់ព្រះចៅមន្ធាតុបរមចក្រពត្តិក៏ត្រូវវិនាសទៅ ខណៈនោះជរាក៏ចូលមកបៀតបៀនព្រះសរីរកាយឲ្យគ្រាំគ្រាទ្រុឌទ្រោមទៅ តែធម្មតាសរីរវយវៈមនុស្សជាតទាំងឡាយមិនដែលបែកធ្លាយក្នុងទេវលោកនោះឡើយ ព្រោះហេតុដូច្នោះ ព្រះចៅមន្ធាតុបរមចក្រពត្តិ ក៏ត្រូវចុតិឃ្លាតចាកទេវលោកចុះមកនៅក្នុងព្រះរាជឧទ្យាន ។

ចំណែកឧយ្យានបាល (អ្នករក្សាសួន) បានឃើញស្ដេចមន្ធាតុរាជ-ស្ដេចមកនៅក្នុងឧទ្យានដូច្នោះ នាំសេចក្ដីនោះទៅក្រាបបង្គំទូលដល់រាជ-ត្រកូល ៗ ក៏នាំគ្នាមកកាត់តែងទីព្រះក្រឡាបន្ទំក្នុងព្រះរាជឧទ្យាន ថ្វាយព្រះចៅមន្ធាតុបរមចក្រពត្តិផ្ទំជាអនុដ្ឋានសេយ្យាសន៍ ។

ក្នុងខណៈនោះ ពួកសេវកាមាត្យទាំងឡាយនាំគ្នាក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គជាសម្មតិទេវរាជ ឥឡូវនេះព្រះអង្គនឹងឲ្យខ្ញុំទូលបង្គំទាំងឡាយធ្វើដូចម្ដេចក្នុងទីចំពោះព្រះភក្ត្រព្រះអង្គ ? ព្រះចៅមន្ធាតុបរមចក្រពត្តិត្រាស់ថា អ្នកទាំងឡាយចូរឲ្យដំណឹងនេះដល់មហាជនឲ្យបានដឹងគ្រប់គ្នាថា ព្រះចៅមន្ធាតុបរមចក្រពត្តិបានសោយរាជសម្បត្តិជាបរមចក្រពត្រាធិរាជមានឥស្សរភាពផ្សាយទៅក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ ទើបបានទៅសោយទិព្វសម្បត្តិក្នុងជាន់ចាតុម្មហា-រាជិកាក៏យូរអង្វែង ទាំងបានឡើងទៅសោយទិព្វសម្បត្តិក្នុងតាវត្តិង្សទេវ-លោក រហូតដល់អស់អាយុរបស់ព្រះឥន្ទ្រ ៣៦ ព្រះអង្គ ក៏នៅមិនអាចនឹងញុំាងសេចក្ដីត្រេកអរ សេចក្ដីប្រាថ្នាក្នុងកាមារម្មណ៍ឲ្យពេញព្រះទ័យបាន ដល់ទីបំផុតក៏ត្រូវចុតិយ្យាតចាកទេវលោកចុះមកផ្ទំក្នុងព្រះរាជឧទ្យាន ឥឡូវនេះស្ដេចទិវង្គតហើយ ។ ព្រះចៅមន្ធាតុបរមចក្រពត្តិមានព្រះរាជត្រាស់ផ្ដាំដូច្នេះហើយក៏ស្ដេចទិវង្គតទៅតាមយថាកម្មរបស់ព្រះអង្គ ។

សត្ត ឥមំ ជម្ពុទេសំ អាហរិត្វា សម្តេចព្រះបរម-សាស្តាចារ្យទ្រង់នាំព្រះធម្មទេសនាគឺជាតកនេះមកសំដែងហើយ ទើប-ត្រាស់នូវបទព្រះគាថាទាំងឡាយដូចតទៅនេះ

យាវតា ចន្ទិមសុរិយា បរិហរន្តិ ទិសា ភន្តិ វិរោចមានា
សព្វេវ ទាសា មន្ធាតុ យេ បាណា បថវិនិស្សិតា
ន កហាបណវស្សេន តិត្តិ កាមេ ន វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ
អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

សេចក្តីថា ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយកាលរះឡើងដើរវិលវង់ក្បែរភ្នំសិនេរុរាជ មានរស្មីដ៏ភ្លឺស្វាងរុងរឿងផ្សាយទៅក្នុងទិស ទាំង ១០ ដោយមិនមានកំណត់ត្រឹមណា សត្វគឺមនុស្សទាំងឡាយដែលអាស្រ័យនៅលើផែនដីក្នុងទីមានកំណត់ត្រឹមណោះ ជាខ្ញុំព្រះចៅមន្ធាតុរាជទាំងអស់ ព្រះចៅមន្ធាតុរាជកាលទ្រង់មានព្រះរាជបំណងនឹងសង្គ្រោះដល់មនុស្សដែលជាខ្ញុំទាំងប៉ុណ្ណោះ ទ្រង់ទះព្រះហស្តក្នុងកាលណា ក្នុងកាលណោះ ភ្លៀងកែវទាំង ៧ ប្រការក៏បវត្តនាការធ្លាក់ចុះមក សូម្បីយ៉ាងនោះ សេចក្តីឆ្អែតក្នុងវត្ថុកាមនិងកិលេសកាម ក៏នៅមិនល្មមដល់ព្រះចៅមន្ធាតុរាជនោះ ក៏បណ្ឌិតកាលដឹងច្បាស់ថា កាមទាំងឡាយមានសេចក្តី

ត្រេកអរតិច គឺមានសេចក្ដីសុខតិច ប្រកបទៅដោយសេចក្ដីទុក្ខច្រើន ដូច្នេះ ក៏មិនមានសេចក្ដីត្រេកអរក្នុងកាមទាំងឡាយ ១ ទៀត សាវ័ករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ សូម្បីមានគេមកអញ្ជើញដោយកាមដ៏ជាទិព្វទាំងឡាយ លោកក៏មិនមានសេចក្ដីប្រាថ្នានឹងត្រេកអរក្នុងកាមដ៏ជាទិព្វនោះឡើយ លោកប្រាថ្នាត្រេកអរតែក្នុងព្រះនិព្វានធម៌ដែលជាទីអស់ទៅនៃតណ្ហា ដោយចំណែកមួយប៉ុណ្ណោះ ។

កាលសម្ដេចព្រះបរមសាស្ដា ទ្រង់នាំអតីតនិទានមកត្រាស់ទេសនាយ៉ាងនេះហើយ ទើបទ្រង់ប្រកាសនូវអរិយសច្ចទាំងឡាយ លុះចប់អរិយសច្ចហើយ ភិក្ខុដែលអផ្សុកនោះក៏បានសម្រេចសោតាបត្តិផល ព្រមទាំងភិក្ខុទាំងឡាយដទៃក៏បានសម្រេចផលមានសោតាបត្តិផលជាដើម ទើបសម្ដេចព្រះលោកុត្តមាចារ្យទ្រង់ប្រជុំជាតកថា ព្រះចៅមន្ធាតុរាជចក្រពត្តិក្នុងគ្រានោះ គឺអត្តភាពតថាគតហ្នឹងឯង ។

ចប់មន្ធាតុរាជជាតក ។